សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ចំណែកមត៌ក និងការសម្រួលចំណែកមត៌ក

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ក. គីម រតនា**

**ក. សុខ សិម្មួយ**

សាស្ត្រាចារ្យណែនាំ

លោក **គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គឹម រតនា** និង នាងខ្ញុំឈ្មោះ **សុខ សិម្ហយ** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំឱនកាយដោយកិច្ចប្រណិប័តន៍ សម្តែងនូវការដឹងគុណ កតញ្ញូដ៏ជ្រាលជ្រៅបំផុតចំពោះ៖**

អ្នកម្តាយ **ខ៉ាន ចន្ទ** និងលោក ឪពុក **គឹម គន់** ជាទីគោរព ដែលបានផ្តល់ឱកាសឲ្យកូនមានជីវិតរស់រាន ព្រមទាំង ខិតខំតស៊ូ លំបាក ព្យាយាម អត់ធ្មត់ ចិញ្ចឹមបីបាច់ ទំនុកបម្រុង ព្រមទាំងលើកទឹកចិត្ត និងផ្តល់នូវអ្វីគ្រប់យ៉ាងដល់កូន មិនថាកំលាំងកាយ កំលាំងចិត្ត ការស្រលាញ់ ឬ សម្ភារៈក្នុងការសិក្សា។ មួយវិញទៀត កូនសូមអរគុណដល់លោកទាំងពីរ ដែលបានខិតខំប្រៀនប្រដៅ និងអត់ឱនរាល់កំហុសដល់រូបកូនតាំងពីកុមារភាព រហូតមកដល់កូនពេញវ័យប្រកបដោយព្រហ្មវិហារធម៌ទាំងបួនគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ចំពោះកូនជានិច្ច ។

អ្នកម្តាយ **សុខ ស្រីពៅ** និងលោកឪពុក **គឹក គ្រី** ជាទីស្រលាញ់ ដែលបានផ្តល់កំណើតឲ្យកូន ព្រមទាំង លោកយាយ **គ័ន ឡូច** ដែលបានតស៊ូលំបាកព្យាយាម ក្នុងការចិញ្ចឹមបីបាច់ចៅព្រមទាំង ជួយទំនុកបម្រុង ទាំងផ្នែកស្មារតី និងសម្ភារៈ ហើយផ្តល់នូវការអប់រំដោយក្តីមេត្តាធម៌ ក៏ដូចជាការជម្រុញទឹកចិត្តឲ្យចៅចេះតស៊ូ ព្យាយាមក្នុងការរៀនសូត្ររហូតមកដល់ថ្នាក់បរិញ្ញាបត្រនេះ។

**ថ្នាក់ដឹកនាំ** ក៏ដូចជា **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិក** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំយ៉ាងយកចិត្តទុកដាក់នូវគ្រប់មុខវិជ្ជា ព្រមទាំង រៀបចំទីតាំងផ្តល់ភាពងាយស្រួលនានាក្នុងការក្រេបយកចំណេះដឹងនាពេលកន្លងមក។ ជាមួយគ្នានេះ យើងខ្ញុំ សូមថ្លែងអំណរគុណជាពិសេសចំពោះ **លោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ** ជាសាស្ត្រាចារ្យណែនាំ ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងការពន្យល់ណែនាំ ផ្តល់ឯកសារ និងដឹកនាំពីរបៀបសរសេរសារណា ក៏ដូចជាការផ្តល់នូវមតិយោបល់ល្អៗដើម្បីធ្វើឲ្យសារណានេះលេចចេញជារូបរាងឡើង។

ជាចុងក្រោយនេះយើងខ្ញុំ សូមលើកហត្ថប្រណមបួងសួងដល់ទេវតា និងវត្ថុសក្តិសិទ្ធិទាំងពួងទាំងអស់ដែលមាននៅក្នុងលោក សូមជួយថែរក្សាលោកអ្នកមានគុណ លោកសាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់ឲ្យជួបប្រទះនឹងពុទ្ធពរទាំង ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ និងប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ព្រមទាំងជោគជ័យរាល់ភារកិច្ចជានិច្ច។

## អារម្ភកថា

ក្រោយពីបានធ្វើការសិក្សាស្វែងយល់អំពីមូលដ្ឋានគ្រឹះ ទ្រឹស្ដី ព្រមទាំងមុខវិជ្ជាដែលទាក់ទងទៅនឹងនីតិសាស្រ្ត រយៈពេល៤ឆ្នាំកន្លងមក សារណានេះបានធ្វើឡើងក្នុងឱកាសនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ ការសរសេរសារណានេះ ជាឱកាសដ៏ពិសេសមួយ ដើម្បីប្រើប្រាស់នូវចំណេះដឹង និងការបញ្ចេញសមត្ថភាព ដែលបានសិក្សាកន្លងមក ធ្វើការស្រាវជ្រាវ និងដោះស្រាយនូវបញ្ហាសង្គមដែលកំពុងតែកើតមានឡើងពាក់ព័ន្ធនឹងវិស័យច្បាប់នៅកម្ពុជា។ ចំពោះប្រធានបទដែលនឹងលើកយកមកបង្ហាញគឺមានចំណងជើងថា "**ចំណែកមត៌ក និងការសម្រួលចំណែកមត៌ក**"។ ការលើកយកប្រធានបទនេះមកសិក្សាស្រាវជ្រាវគឺ ក្នុងគោលបំណងដើម្បីយល់ដឹងបន្ថែមឲ្យបានស៊ីជម្រៅអំពីការបែងចែកមតិកចំពោះសន្តតិជននីមួយៗអោយមានភាពស្មើគ្នានិងមានភាពយុត្តិធម៌។

គួររំលឹកផងដែរថា នៅក្នុងប្រទេសកម្ពុជា របបសន្តតិកម្ម កើតមានតាំងពីយូរយាណាស់មកហើយ ក្នុងរូបភាពជាការអនុវត្តតៗគ្នា។ រហូតមកដល់ឆ្នាំ ១៩២០ ទើបប្រទេសកម្ពុជាមានក្រមរដ្ឋប្បវេណី ដើម្បីធ្វើការគ្រប់គ្រងទៅលើនីតិឯកជន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការគ្រប់គ្រងទៅលើរបបនៃសន្តតិកម្ម ចំពោះការបែងចែកមតិក ពុំទាន់មានភាពត្រឹមត្រូវនោះទេ ព្រោះច្បាប់នាសម័យនោះនៅមានភាពរើសអើងទៅលើស្រ្តី ព្រមទាំងកូនមួយចំនួន។ ដោយមានការកែប្រែ និងស្របតាមបច្ចុប្បន្នភាពរបស់សង្គម នៅក្នុងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ មានចែងយ៉ាងច្បាស់លាស់អំពីរបបនៃសន្តតិកម្ម ព្រមទាំងការពារ និងផ្តល់នូវភាពយុត្តិធម៌ ដល់សន្តតិជនគ្រប់រូបចំពោះការបែងចែកនូវមតិក ដែលជាសក្ខីកម្មដ៏សំខាន់សម្រាប់ស្រាវជ្រាវទៅលើប្រធានបទខាងលើនេះ។

សារណានេះក៏ជាផ្លែផ្កាមួយ ដែលកើតចេញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនទៅលើសន្តតិកម្ម ដែលផ្តោតយ៉ាងសំខាន់ទៅលើ ពីរចំនុចគឺ ចំណែកមតិករបស់សន្តតិជនក្នុងការទទួលបានសន្តតិកម្ម និងការសម្រួលចំណែកមតិកចំពោះភាពមិនយុត្តិធម៌ចំពោះសន្តតិជនមួយចំនួន។

ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែសមត្ថភាព និងបទពិសោធន៍ ព្រមទាំងចំណេះដឹង នូវមានកម្រិតនៅឡើយ សារណានេះគង់តែមានចំនុចខ្វះខាតតិច ឬច្រើនដោយមិនអាចជៀសបាន។

ជាទីបញ្ចប់យើងខ្ញុំសង្ឃឹមថាអស់លោក លោកស្រី សាស្រ្តាចារ្យអ្នកជំនាញ និស្សិតទាំងអស់នឹងផ្តល់ការរិះគន់ក្នុងន័យស្ថាបនា ព្រមទាំងផ្តល់នូវមតិកែលម្អនានាដើម្បីឲ្យសារណានេះបានជាប្រយោជន៍ដល់និស្សិតជំនាន់ក្រោយជាក់ជាមិនខាន។

# មាតិកា

**សេចក្តីផ្តើម**......................................................................... ១

**ជំពូកទី ១៖ សន្តតិជន និងចំណែកមត៌ក**......................................................................... ៥

**ផ្នែកទី ១៖ សន្តតិជន**......................................................................... ៥

១. លក្ខណសម្បត្តិជាសន្តតិជន......................................................................... ៥

១.១ ជនដែលមានជីវិតរស់នៅ......................................................................... ៦

១.២ អភ័ព្វបុគ្គល......................................................................... ៧

១.២.១ ការធ្វើឃាតដោយចេតនា ឬ ប៉ុនប៉ងធ្វើឃាតលើជនជាប់ពាក់ព័ន្ធនៅក្នុងសន្តតិកម្ម........ ៨

១.២.២ ការដឹងអំពីការសម្លាប់មតកជន តែមិនរាយការណ៍ ឬ មិនបានប្តឹង......................... ៨

១.២.៣ ការរារាំងមតកជនទាក់ទងមតកសាសន៍......................................................................... ៩

១.២.៤ ការគម្រាមកំហែង ឬឆបោកមតកជនឲ្យធ្វើ លុបចោល ឬកែប្រែ មតកសាសន៍........ ៩

១.២.៥ ក្លែងបន្លំ ឬ បំផ្លាញចោល ឬ លាក់ទុកមតកសាសន៍......................................................................... ១០

១.៣ ជនផ្តាច់ចេញពីសន្តតិជន......................................................................... ១០

១.៣.១ ធ្វើបាបមតកជន......................................................................... ១០

១.៣.២ ប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ......................................................................... ១០

១.៣.៣ មានលទ្ធភាពមកមើលថែមតកជន តែមិនមក......................................................................... ១១

១.៣.៤ ជាប់ពន្ធនាគារមួយជីវិត......................................................................... ១១

១.៣.៥ ប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់......................................................................... ១២

១.៤ សន្តតិជនជាជនបរទេស......................................................................... ១២

២. លំដាប់នៃសន្តតិជន......................................................................... ១៣

២.១ សន្តតិជនលំដាប់ទី ១......................................................................... ១៣

២.២ សន្តតិជនលំដាប់ទី ២......................................................................... ១៥

២.៣ សន្តតិជនលំដាប់ទី ៣......................................................................... ១៥

២.៤ សហព័ទ្ធ......................................................................... ១៦

**ផ្នែកទី ២ ៖ ចំណែកមត៌ករបស់សន្តតិជន** ........ ១៧
១. ចំណែកមតិកតាមច្បាប់ ........ ១៧
១.១ សន្តតិជនជាបច្ឆាញាតិផ្ទាល់ ........ ១៧
១.២ សន្តតិជនជាបុព្វញាតិផ្ទាល់ ........ ១៨
១.៣ សន្តតិជនជាបងប្អូនបង្កើត ........ ១៩
១.៣.១ បងប្អូនរួមឪពុកម្តាយ ........ ១៩
១.៣.២ បងប្អូនរួមតែឪពុក ឬ ម្តាយ ........ ១៩
១.៤ សន្តតិជនជាសហព័ទ្ធ ........ ២០
១.៤.១ សហព័ទ្ធ និងបច្ឆាញាតិ ........ ២១
១.៤.២ សហព័ទ្ធ និងបុព្វញាតិ ........ ២១
១.៣ សហព័ទ្ធ និងបងប្អូនបង្កើត ........ ២២
២. ចំណែកមតិករបស់សន្តតិជនក្នុងករណីមានបណ្តាំ ........ ២២
២.១ ការកំណត់ចំណែកមតិក ........ ២២
២.១.១ វិធីកំណត់តាមសមាមាត្រ ........ ២២
២.១.២ វិធីកំណត់នូវទ្រព្យជាក់ស្តែង ........ ២៣
២.១.៣ វិធីកំណត់ចំណែកមតិកសម្រាប់សហសន្តតិជនផ្សេងទៀត ........ ២៣
២.២ ការកំណត់វិធីបែងចែក ........ ២៣
២.២.១ បុគ្គលដែលអាចកំណត់វិធីបែងចែក ........ ២៤
២.២.១.១ ការកំណត់នូវវិធីបែងចែកដោយមតកជនផ្ទាល់ ........ ២៤
២.២.១.២ ការប្រគល់អាណត្តិឲ្យតតិយជន ........ ២៤
២.២.២ កម្មវត្ថុ ........ ២៥
២.២.៣ លក្ខខណ្ឌ ........ ២៥
២.២.៤ វិធីបែងចែកមតិក ........ ២៦
២.២.៤.១ ការបែងចែកមតិកជាវត្ថុជាក់ស្តែង ........ ២៦

២.២.៤.២ ការបែងចែកមត៌កជាតម្លៃថ្នូរ ២៧
២.២.៤.៣ ការបែងចែកមត៌កដោយការប្តូរជាប្រាក់ ២៧
**ជំពូកទី ២៖ ការសម្រួលចំណែកមត៌ក** ២៨
**ផ្នែកទី ១៖ ផលប្រយោជន៍ពិសេស** ២៨
១. សញ្ញាណនៃផលប្រយោជន៍ពិសេស ២៨
១.១ ប្រទានកម្មក្នុងឱកាសពិសេស ២៩
១.១.១ អាពាហ៍ពិពាហ៍ ៣០
១.១.២ ហេតុការណ៍ផ្សេងៗ ៣១
១.២ មូលធននៃជីវភាពរស់នៅ ៣២
១.៣ អច្ច័យទាន ៣៣
២. តម្លៃនៃផលប្រយោជន៍ពិសេស ៣៣
២.១ ករណីបាត់បង់ ឬវិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម ៣៤
២.២ ករណីកើនឡើងនៃតម្លៃប្រទានកម្ម ៣៤
៣. វិធីនៃការសម្រួលចំណែកមត៌ក ៣៥
៣.១ តម្លៃនៃមត៌កក្នុងករណីមានផលប្រយោជន៍ពិសេស ៣៦
៣.២ ចំណែកមត៌ករបស់សន្តតិជនក្នុងករណីមានផលប្រយោជន៍ពិសេស ៣៦
៣.២.១ ករណីទូទៅ ៣៦
៣.២.២ ក្នុងករណីតម្លៃនៃផលប្រយោជន៍ពិសេសលើសពីចំណែកមត៌ក ៣៧
**ផ្នែកទី២៖ ភាគនៃវិភាគទាន** ៣៩
១. និយមន័យ និងគោលគំនិត ៣៩
២. ប្រភេទនៃវិភាគទាន ៤០
២.១ ការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ៤០
២.២ ការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ៤០
២.៣ ការថែទាំព្យាបាលមតកជន ៤១

២.៤ វិធីផ្សេងៗទៀត ........ ៤១
៣. វិធីនៃការសម្រួលចំណែកមត៌ក ........ ៤១
៣.១ ការគណនាតម្លៃនៃមត៌កក្នុងករណីមានភាគនៃវិភាគទាន ........ ៤២
៣.២ ចំណែកមត៌ករបស់សន្តតិជនដែលបានធ្វើភាគនៃវិភាគទាន ........ ៤២
៤. តម្លៃនៃវិភាគទាន ........ ៤៣
៤.១ ការពិភាក្សាគ្រប់សហសន្តតិជន ........ ៤៣
៤.២ ការកំណត់ភាគនៃវិភាគទានដោយតុលាការ ........ ៤៤
**សេចក្តីសន្និដ្ឋាន** ........ ៤៥
**អនុសាសន៍** ........ ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

របបសន្តតិកម្ម ត្រូវបានស្រាវជ្រាវឃើញថា មានចាប់តាំងពីសម័យដើមមកម្ល៉េះ។ កាលពីសម័យមុន សន្តតិកម្មត្រូវបានគេចាត់ទុកថាជាការផ្ទេរនូវការកាន់កាប់ ការប្រគល់នូវទ្រព្យសម្បត្តិ ឬ ជាការស្នងតំណែងណាមួយ ពីម្នាក់ទៅម្នាក់ទៀត ដែលពួកគេទាំងពីរមានទំនាក់ទំនងសាច់ញាតិនឹងគ្នា។ តួយ៉ាង របបសន្តតិកម្ម មានចាប់តាំងពីសម័យនគរភ្នំ ដែលឆ្លងតាមរយៈការប្រើប្រាស់ទំនៀមទម្លាប់តៗគ្នាដូចជាចំពោះព្រះមហាក្សត្រ គឺការផ្ទេររាជបល្ល័ងពីឪពុក ទៅកូន ឬ ពីបងទៅប្អូន។ ការធ្វើបែបនេះគឺឆ្លងពីសម័យកាលមួយទៅសម័យកាលមួយ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ក៏ការអនុវត្តន៍នៃរបបនេះមិនស្ថិតស្ថេរដែរ វាត្រូវបានប្រែប្រួល និងវិវឌ្ឍទៅតាមសម័យកាល រហូតមកដល់សម័យព្រះរាជាណាចក្រកម្ពុជាស្ថិតក្រោមអាណាព្យាបាលរបស់បារាំង។

ឆ្លងកាត់តាមការខិតខំតស៊ូពុះពារជាច្រើនឆ្នាំដើម្បីអភិវឌ្ឍវិស័យច្បាប់ ប្រទេសកម្ពុជាចាប់ផ្តើមមានក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលទទួលឥទ្ធិពលទាំងស្រុងពីច្បាប់ប្រទេសបារាំង។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ប្រទេសកម្ពុជារីករាយនឹងទទួលក្រមនេះ ព្រោះវាជាច្បាប់ដើម្បីគ្រប់គ្រងលើវិស័យឯកជន នឹងផ្តោតជាពិសេសទៅលើរបបសន្តតិកម្ម។ ជាលទ្ធផលនៃការអនុម័តក្រមរដ្ឋប្បវេណីនេះ ដោយមានឥទ្ធិពលពីច្បាប់បច្ចឹមប្រទេស បានធ្វើឲ្យច្បាប់ខ្មែរសម័យមុនៗត្រូវបានកែប្រែយ៉ាងច្រើន រួមទាំងការអនុវត្តន៍មួយចំនួន ដែលនាំឲ្យប្រព័ន្ធនៃការបែងចែកទ្រព្យសម្បត្តិកាន់តែមានភាពច្បាស់លាស់និងយុត្តិធម៌សម្រាប់សន្តតិជននីមួយៗ។

ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ មានចែងអំពី របបសន្តតិកម្មយ៉ាងនេះក្តី ក៏ច្បាប់នេះមិនអាចគ្រប់គ្រងទាំងស្រុងទៅលើទិដ្ឋភាពជាក់ស្តែងក៏ដូចជាការវិវឌ្ឍន៍ពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងសង្គមដែរ។ ជាក់ស្តែង ចំណែកមត៌ក នៅតែមានបញ្ហាកើតឡើង ព្រោះប្រទេសកម្ពុជាមិនទាន់ឲ្យតម្លៃទូលាយទៅលើស្ត្រីជាភរិយា កូនស្រី ឬ កូនរបស់ប្រពន្ធបន្ទាប់ពីប្រពន្ធដើមនោះទេ គេឲ្យតម្លៃតែទៅលើ ភរិយាដែលស្តេចប្រទាន ឬ កូនប្រុសច្បង ឬ កូនដែលកើតចេញពីប្រពន្ធដើមតែប៉ុណ្ណោះ។ ព្រោះដោយសារសម័យនោះជាសម័យព្រះរាជានៅមានអំណាច ហើយមនុស្សនៅក្នុងសង្គមនោះមានគំនិតគិតថា ស្ត្រីគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ឬ ចាត់ចែងទ្រព្យសម្បត្តិនោះទេ ដែលជាមូលហេតុនាំឲ្យមានពាក្យមួយឃ្លាថា "ស្ត្រីបង្វិលចង្ក្រានមិនជុំ"។ ជាមួយគ្នានោះ ដោយសារបុរសនាពេលនោះមានសិទ្ធិយកប្រពន្ធច្រើនបានបែបនេះ។ មូលហេតុនេះហើយទើបធ្វើឲ្យការធ្វើសន្តតិកម្មម្តងៗ តែងតែមានការរើសអើងទាយាទផ្សេងទៀត ដែលនៅក្នុងសង្គមនោះមិនឲ្យតម្លៃហើយទាយាទដែលមតកជនស្រលាញ់ពេញចិត្ត ត្រូវបានចំណែកមត៌កទាំងអស់ ឬ បានច្រើនភាគជាងគេ ដែលជារឿយៗតែងតែបង្កនូវជម្លោះក្នុងការដណ្តើមមត៌ករវាងបងប្អូនរួមឪពុក ឬ រួមម្តាយ

ជាមួយគ្នា ព្រោះការធ្វើបែបនេះ ពិតជាអយុត្តិធម៌ខ្លាំងណាស់ក្នុងការបែងចែងទ្រព្យសម្បត្តិ ដោយជួនកាលកូនដែលកើតចេញពីប្រពន្ធចុង បែរជាមិនបានទទួលអ្វីទាល់តែសោះពីមតកជន ទោះបីកូននោះជាឈាមបង្កើតរបស់មតកជនក៏ដោយ។ ទន្ទឹមនឹងនេះផងដែរ មានករណីខ្លះទៀត កូនមួយចំនួនរបស់មតកជនបានទទួលនូវទ្រព្យសម្បត្តិមុនការចាប់ផ្តើមសន្តតិកម្ម ដោយជាប្រទានកម្មរបស់មតកជនផ្ទាល់។ ក្រោយមកនៅក្នុងបណ្តាំមតិក មតកជនបានផ្តល់នូវមតិកដល់កូនដែលទទួលប្រទានកម្មនោះម្តងទៀត។ ប៉ុន្តែ ចំពោះសន្តតិជន ដ៏ទៃទៀតវិញគឺមិនបានទទួលចំណែកមតិកសូម្បីតែបន្តិច។ ដោយមិនអាចទ្រាំទ្រនឹងភាព អយុត្តិធម៌ដ៏ខ្លាំងនេះ ក្នុងនាមជាសន្តតិជនដូចគ្នាសន្តតិជនដ៏ទៃទៀតតែងតែងើបឡើងប្រឆាំងទាមទារសិទ្ធរបស់ខ្លួន ដើម្បីក្លាយជាម្ចាស់មតិកមួយចំណែករបស់មតកជនដែលជាឪពុកម្តាយរបស់ខ្លួន។

ស្របពេលដែលការទាមទារសិទ្ធរបស់សន្តតិជនទាំងអស់នោះ ត្រូវបានគេទទួលស្គាល់ជាបណ្តើរៗ។ ជាអកុសល នៅក្នុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបដ៏ខ្មៅងងឹត ដែលត្រូវបានគេស្គាល់ថាជាសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសម័យនោះ ប្រព័ន្ធច្បាប់ខ្មែរស្ទើរតែទាំងអស់ត្រូវបានផ្លាស់ប្តូរ ដោយទ្រព្យសម្បត្តិឯកជនទាំងអស់មិនត្រូវអនុញ្ញាតឲ្យប្រើប្រាស់ដោយប្រជាពលរដ្ឋនោះទេ។ ប្រជាពលរដ្ឋទាំងអស់ គ្មានកម្មសិទ្ធិផ្ទាល់ខ្លួន គ្មានការផ្ទេរ គ្មានការកាន់កាប់ គ្មានការធ្វើសន្តតិកម្មអ្វីទាំងអស់។ ប៉ុន្តែក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមក ប្រព័ន្ធច្បាប់និង ការគ្រប់គ្រងនៅក្នុងប្រទេសកម្ពុជាមានការផ្លាស់ប្តូរ និងវិវឌ្ឍគួរអោយកត់សម្គាល់ ។

ក្រោយមក នៅក្នុងឆ្នាំ ១៩៩៩ ដោយមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសជប៉ុន ប្រទេសកម្ពុជាបានបង្កើតក្រមរដ្ឋប្បវេណីថ្មីមួយឡើងគឺ **ក្រមរដ្ឋប្បវេណី** ហើយត្រូវបានប្រកាសឲ្យប្រើនៅក្នុងឆ្នាំ ២០០៧។ ការបង្កើតក្រមនេះឡើងមក គឺក្នុងគោលដៅដើម្បីគ្រប់គ្រងសង្គមស្របទៅតាមភាពជឿនលឿននៃសកលលោក ព្រមទាំងសម្រាប់អនុវត្តនាពេលអនាគតផងដែរ។ ប៉ុន្តែ ដោយសារតែប្រទេសកម្ពុជាយើងទើបតែងើបពីសង្គ្រាមស៊ីវិល ធនធានមនុស្សសំខាន់ៗស្ទើរតែទាំងអស់ត្រូវបាត់បង់ទើបធ្វើឲ្យការផ្សព្វផ្សាយ និងការអនុវត្តន៍ ជួបនូវបញ្ហាជាច្រើន ព្រោះចំណេះដឹងនៃប្រជាពលរដ្ឋមានកម្រិត ធ្វើឲ្យពួកគាត់មិនសូវយល់ច្បាប់ពីបញ្ញត្តិនៃក្រមនេះ ហើយប្រើប្រាស់មិនសូវត្រឹមត្រូវទៅតាមគោលដៅនៃការបង្កើតនោះទេ។ ជាពិសេស គឺពាក់ព័ន្ធនឹងចំនុចចំណែកមតិក និងការសម្រួលចំណែកមតិក ដែលក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧នេះតែម្តង។

តួយ៉ាងនៅក្នុងក្រមរដ្ឋប្បវេណីថ្មីនេះបានឲ្យនិយមន័យនៃចំណែកមត៌ក គឺជាចំនួន ឬ ចំណែកមត៌កដែលសន្តតិជនទទួលបានពីសន្តតិកម្ម។ ចំណែកឯ ការសម្រួលចំណែកមត៌ក គឺជាការសម្រួលនូវចំណែកមត៌កដែលសន្តតិជនបានទទួលនូវប្រទានកម្មពិសេស ដែលនៅក្នុងក្រមថ្មីហៅថា ផលប្រយោជន៍ពិសេស ដែលប្រើប្រាស់ក្នុងគោលបំណងធានាឲ្យមានតុល្យភាពនៃចំណែកមត៌កចំពោះសន្តតិជនផ្សេងទៀត។ ប៉ុន្តែ ជាមួយគ្នានោះនៅតែមានចំណោទបញ្ហាជាច្រើនបានចោទឡើងថា តើសន្តតិជនម្នាក់នឹងៗទទួលបានសន្តតិកម្មប៉ុន្មាន? នឹងមួយវិញទៀត ប្រសិនបើសន្តតិជនបានទទួលនូវផលប្រយោជន៍ពិសេស មុនការចាប់ផ្តើមសន្តតិកម្ម តើត្រូវមានដំណោះស្រាយបែបណា? តើទំហំនៃប្រទានកម្មកម្រិតណាទើបហៅថាផលប្រយោជន៍ពិសេស ?

សារណានេះមានគោលបំណងធ្វើឡើងដើម្បីសិក្សាស្រាវជ្រាវ ទៅលើរបបនៃសន្តតិកម្មដែលជាក់ស្តែងដែលភាគច្រើនខ្លឹមសារនៃច្បាប់នេះបានផ្សារភ្ជាប់ទៅនឹងច្បាប់នៃប្រទេសជប៉ុន និងទិដ្ឋភាពសង្គមប្រទេសកម្ពុជាបច្ចុប្បន្នដែលឲ្យតម្លៃស្ត្រី និងបុរស និងសិទ្ធិទទួលមត៌ករវាងសន្តតិជន និងសន្តតិជន ដែលមានភាពខុសគ្នាតិចតួចទៅនឹងទំនៀមទម្លាប់ពីសម័យមុន និងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០។ លើសពីនេះទៅទៀត ការស្រាវជ្រាវនៅក្នុងសារណារមួយនេះនឹងអាចក្លាយជាប្រទីបមួយចូលរួមក្នុងការអភិវឌ្ឍន៍ វិស័យច្បាប់នៅក្នុងប្រទេសកម្ពុជា ដោយសិក្សា និងសាកល្បងដាក់ចេញជាដំណោះស្រាយដើម្បីដោះស្រាយបញ្ហាដែលកំពុងជួបប្រទះនៅពេលនេះ។

មួយវិញទៀតប្រធានបទក្នុងសារណានេះ ស្រាវជ្រាវត្រឹមតែការដោះស្រាយនូវបញ្ហាមួយចំនួននៅក្នុងប្រទេសកម្ពុជា និងផ្តោតសំខាន់តែទៅលើចំនុចសំខាន់ៗមួយចំនួននៃសន្តតិកម្ម ដូចជាការបង្ហាញពីនរណាជាសន្តតិជន រួចបង្ហាញពីចំណែកដែលពួកគេបានទទួល ក្រោយមកប្រសិនបើសន្តតិជនមួយចំនួនទទួលបាននូវផលប្រយោជន៍ពិសេស ហើយសន្តតិជនមួយចំនួនទៀតមិនទទួលបាន នឹងមានដំណោះស្រាយបែបណាដើម្បីឲ្យមានសុក្រឹត្យភាព ព្រមទាំងការបង្ហាញពីចំណែកមត៌កដែលសន្តតិជនបានធ្វើភាគនៃវិភាគទានចំពោះមតកជន។

ប្រធានបទនៃសារណានេះ ផ្អែកសំខាន់ទៅលើឯកសារកម្រងច្បាប់ថ្មីជាច្រើនដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណី ក៏ដូចជាក្រមរដ្ឋប្បវេណីភាគ៦ ព្រមទាំងឯកសារប្រវត្តិសាស្ត្រ និងមេរៀនដែលបានសិក្សាពីសាស្ត្រាចារ្យពីមុនៗមក។ ការស្រាវជ្រាវនេះគ្រាន់តែធ្វើការរៀបរៀង និងខ្លឹមសារនៃច្បាប់នានាដែលពាក់ព័ន្ធ និងធ្វើការវិភាគស្វែងរកលទ្ធផលនានាដោយផ្អែកលើឯកសារនោះទាំងស្រុង ដោយមិនមានការស្រាវជ្រាវបង្កើតឯកសារ និងពត៌មានថ្មីបន្ថែមនោះទេ។

សារណានេះបែងចែកជា ២ ជំពូក។ ជំពូកទី ១ រៀបរាប់អំពី សន្តតិជន និងចំណែកមត៌ក ព្រមទាំងបកស្រាយយ៉ាងក្បោះក្បាយអំពី លក្ខណសម្បត្តិដើម្បីក្លាយទៅជាសន្តតិជន និងលំដាប់នៃសន្តតិជន ក៏ដូចជាចំណែកមត៌កតាមច្បាប់ និងចំណែកមត៌កតាមបណ្តាំ។ ជំពូកទី ២ បកស្រាយអំពីការសម្រួលចំណែកមត៌ក ដែលសិក្សាអំពី ផលប្រយោជន៍ពិសេស ព្រមទាំងភាគនៃវិភាគទានដែលសន្តតិជននីមួយៗសមនឹងទទួលបាន។ ចុងក្រោយ គឺធ្វើការសន្និដ្ឋាន និងព្យាយាមទាញរកមូលដ្ឋានគ្រឹះសំខាន់ៗក្នុងការពិចារណា និងដំណោះស្រាយមួយឲ្យបានសមស្របនៅក្នុងបរិបទកម្ពុជា។

# ជំពូកទី ១៖ សន្តតិជន និងចំណែកមត៌ក

នៅក្នុងព្រះរាជាណាចក្រកម្ពុជា របបសន្តតិកម្មត្រូវបានគេគិតថា ត្រូវបានទទួលស្គាល់តាំងពីយូរលង់ណាស់មកហើយ ដោយផ្អែកទៅលើមូលដ្ឋាននៃរបបទ្រព្យសម្បត្តិឯកជន។ ចំពោះខ្លឹមសារនៃរបបសន្តតិកម្មត្រូវបានផ្លាស់ប្តូរខុសៗគ្នា ទៅតាមសម័យកាលនីមួយៗ។ ជាក់ស្តែង ចំពោះក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្នបានកំណត់សន្តតិកម្ម គឺជាការផ្ទេរសិទ្ធិ និងករណីយកិច្ច របស់បុគ្គលម្នាក់ដែលបានទទួលមរណភាព (ហៅថា មតកជន) បន្តទៅបុគ្គលនៅក្នុងថ្នាក់នៃទំនាក់ទំនងញាតិជាកំណត់មួយ (ហៅថា សន្តតិជន)[1]។

នៅពេលចាប់ផ្តើមសន្តតិកម្ម មានដំណាក់កាលពីរសំខាន់ៗគឺ តើនរណាខ្លះជាសន្តតិជន? (ផ្នែកទី១) និងត្រូវដឹងថាតើមតកជនមានទ្រព្យសម្បត្តិអ្វីខ្លះ ដើម្បីឲ្យងាយស្រួលបែងចែកនូវចំណែករបស់សន្តតិជនម្នាក់ៗ (ផ្នែកទី ២)។

## ផ្នែកទី ១៖ សន្តតិជន

នៅក្នុងទំនាក់ទំនងនៃសន្តតិកម្ម បុគ្គលដែលទទួលបានទ្រព្យសម្បត្តិពីមតកជនតាមរយៈសន្តតិកម្មគេហៅថា សន្តតិជន។ ជាគោលការណ៍សន្តតិជនជា៖

- ជាបុគ្គលដែលស្ថិតនៅក្នុងទំនាក់ទំនងញាតិជាកំណត់ដោយច្បាប់
- ជាអ្នកដែលទទួលបន្ត នូវសិទ្ធិ និងករណីយកិច្ចពីមតកជន
- ជាអ្នកទទួលបន្តនូវឋានៈរបស់មតកជន

ទោះបីជាបានដឹងអំពីសន្តតិជនជាអ្នកណាក៏ដោយ ក៏ប៉ុន្តែមានសំណួរចោទឡើងថា៖

តើត្រូវមានលក្ខណសម្បត្តិបែបណា ដើម្បីក្លាយទៅជាសន្តតិជន (១)? តើគេត្រូវបែងចែកលំដាប់នៃសន្តតិជនយ៉ាងដូចម្តេច (២)?

### ១. លក្ខណសម្បត្តិជាសន្តតិជន

ក្រោយពីមតកជនបានទទួលមរណភាព នោះនឹងមានញាតិជាច្រើនដូចជា បច្ឆាញាតិផ្ទាល់ បុព្វញាតិផ្ទាល់ សហព័ន្ធ ឬ បងប្អូនបង្កើតរបស់មតកជននឹងក្លាយទៅជាសន្តតិជន។ ប៉ុន្តែ មានករណីខ្លះញាតិទាំងនោះមិនត្រូវចាត់ទុកជាសន្តតិជននោះទេ ព្រោះពួកគេមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន។ ដូចនេះ ដើម្បីក្លាយទៅជាសន្តតិជន គឺចាំបាច់ណាស់ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- មានជីវិតរស់នៅ (១.១)

[1] ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ, សេចក្តីផ្តើម នីតិរដ្ឋប្បវេណី ( កែសម្រួល ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០១២), ទំព័រ ១៥៩

- មិនមែនជាអភ័ព្វបុគ្គល (១.២)
- មិនមែនជាជនដែលត្រូវបានផ្តាច់ចេញពីមតិក (១.៣)
- ករណីពិសេស សន្តតិជនជាជនបរទេស (១.៤)

### ១.១ ជនដែលមានជីវិតរស់នៅ

ជាទូទៅ សិទ្ធរបស់មនុស្សគ្រប់រូប ត្រូវបានបញ្ចប់ដោយមូលហេតុមរណភាព។ ដូចនេះ ដើម្បីក្លាយទៅជាសន្តតិជន ក្នុងការទទួលបាននូវសន្តតិកម្ម គឺចាំបាច់ណាស់ត្រូវមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម[2]។ មានន័យថា មិនមានលក្ខណសម្បត្តិជាសន្តតិជនទេ ប្រសិនបើបុគ្គលនោះបានបាត់បង់ជីវិត នៅមុនពេលចាប់ផ្តើម ឬ បានទទួលមរណភាពដំណាលគ្នានឹងមតកជន។ នៅក្នុងចំនុចនេះ ក៏មានករណីលើកលែងផងដែរ ចំពោះបុគ្គលដែលមិនមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម តែនឹងមានជីវិតនាពេលអនាគត។

ជាគោលការណ៍ ទារកនៅក្នុងគភ៌ គឺមិនទាន់មានសមត្ថភាពអាចក្លាយទៅជាម្ចាស់នៃសិទ្ធនោះទេ[3]។ ដូចនេះក្នុងករណីដែល ឪពុកបានទទួលមរណភាព នៅពេលទារកនៅក្នុងគភ៌ គឺកូនមិនអាចទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិរបស់ឪពុកបានឡើយ។ ផ្ទុយទៅវិញ ក្នុងករណីដែល ទារកនៅក្នុងគភ៌ហើយអាចនឹងមានកំណើត តែការកើតនោះមានភាពយឺតជាងការចាប់ផ្តើមសន្តតិកម្មបន្តិច តែបែរជាមិនទទួលស្គាល់នូវសមត្ថភាពទទួលសិទ្ធិ នោះមិនសមរម្យនោះទេ។ ដូចនេះទើបក្រមប្រទេសមួយចំនួនបានចែងអំពី ករណីនៃការទទួល សន្តតិកម្ម ដោយទទួលស្គាល់ករណីលើកលែងនៃសមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ ដូចជា៖

**- ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៩០៦**

(១) ដើម្បីឲ្យមានសមត្ថភាពទទួលនូវប្រទានកម្មរវាងបុគ្គលដែលមានជីវិត ឲ្យតែបុគ្គលនោះនៅក្នុងគភ៌ ជាការគ្រប់គ្រាន់

(២) ដើម្បីឲ្យមានសមត្ថភាពអាចទទួលសន្តតិកម្មដោយមតកសាសន៍ ឲ្យតែបុគ្គលនោះនៅក្នុងគភ៌ពេលដែលម្ចាស់បណ្តាំទទួលមរណភាព ជាការគ្រប់គ្រាន់

(៣) ប៉ុន្តែ ប្រទានកម្ម ឬ មតកសាសន៍នោះមានអានុភាព លុះត្រាតែកូននោះ កើតឡើងដោយមានសមត្ថភាពរស់នៅ។

---

[2] មាត្រា ១១៨៩ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[3] មាត្រា ៩ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១ (គន្លឹះទី ១ –ទី ៣)

**- ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧២១ មាត្រា ៨៨៦ មាត្រា ៩៦៥**

• មាត្រា ៧២១ "ទារកដែលនៅក្នុងពោះរបស់ម្តាយគេ ពាក់ព័ន្ធទៅនឹងការទាមទាររបស់គេទៅលើសំណងនៃការខូចខាត ត្រូវបានចាត់ថាបានកើតរួចមកហើយ"

• មាត្រា ៨៨៦

(១) ចំពោះសន្តតិកម្មទារកដែលនៅក្នុងផ្ទៃរបស់ម្តាយគេ ត្រូវបានចាត់ទុកថាបានកើតរួចមកហើយ។

(២) បទបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើមិនអាចអនុវត្តបានទៅលើករណី ដែលទារកនៅក្នុងផ្ទៃរបស់គេបានកើតមក ហើយស្លាប់នោះទេ។

• មាត្រា៩៦៥ "បទបញ្ញត្តិ នៃមាត្រា ៨៨៦ និង ៨៩១ ត្រូវអនុវត្តលើការផ្លាស់ប្តូរដោយចាំបាច់ ទៅលើអ្នកទទួលអំណោយមតិក។

យ៉ាងណាមិញ ប្រទេសកម្ពុជាក៏បានទទួលស្គាល់នូវការលើកលែង នូវសមត្ថភាពទទួលសិទ្ធរបស់ទារកក្នុងគភ៌ ទាក់ទងនឹងសន្តតិកម្មផងដែរ។ តាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ មាត្រា ៨៨៨ កថាខណ្ឌទី ២ របស់កម្ពុជាបានចែងថា "ទារកដែលនៅក្នុងគភ៌នៅឡើយ បើកើតក្នុងរវាង ៣០០ថ្ងៃ គិតតាំងពីថ្ងៃដែលខ្មោចនោះស្លាប់មក ហើយរស់អាចទទួលនូវសន្តតិកម្មបាន" ។ មួយវិញទៀត ក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ក៏បានទទួលស្គាល់សមត្ថភាពទទួលសិទ្ធ របស់ទារកក្នុងការទទួលសន្តតិកម្ម។ ក្នុងករណីដែល ទារកដែលនៅក្នុងគភ៌នាពេលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ នោះអាចទទួលមតិកដោយសន្តតិកម្ម។ ម៉្យាងវិញទៀតក្នុងករណីដែលមានបណ្តាំមតិក ប្រសិនបើទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទើបទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន។[4]

**១.២ អភ័ព្វបុគ្គល**

អភ័ព្វបុគ្គល[5] គឺជាជនដែលច្បាប់កម្រិតថាមិនអាចក្លាយទៅជាសន្តតិជន ហើយក៏មិនអាចទទួលបាននូវមតិកពីមតកជនបានដែរ ព្រោះអភ័ព្វបុគ្គល គឺជាបុគ្គលដែលបានធ្វើអោយប៉ះពាល់នូវសណ្តាប់ធ្នាប់សាធារណៈ។ ជាមួយគ្នានេះ នៅក្នុងមាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានកំណត់អំពីអំពើមួយចំនួនដែលសន្តតិជនណាម្នាក់ត្រូវបានប្រព្រឹត្ត ហើយត្រូវបានសន្មត់ថាជាអភ័ព្វបុគ្គល ដូចខាងក្រោម៖

[4] មាត្រា ៩ កថាខណ្ឌទី ២ និងទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[5] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី លេខ ១៩០, ទំព័រ ២៧

### ១.២.១ ការធ្វើឃាតដោយចេតនា ឬ ប៉ុនប៉ងធ្វើឃាតលើជនជាប់ពាក់ព័ន្ធនៅក្នុងសន្តតិកម្ម

នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាល់បុគ្គលដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ សុទ្ធតែត្រូវជាប់ទោសព្រហ្មទណ្ឌ ហើយរាល់ការទទួលទោសព្រហ្មទណ្ឌ ត្រូវតែមានការចេញសាលក្រមជាស្ថាពពីតុលាការ។ ជាក់ស្តែង បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាង ឬ លំដាប់ស្មើគ្នា ជាអភ័ព្វបុគ្គលនៃសន្តតិកម្ម។ នេះមានរួមទាំងករណីដែលបានធ្វើដោយផ្ទាល់ និងករណីដែលត្រូវផ្តន្ទាទោស ដោយសារបានជួយ ឬ សមគំនិតក្នុងការធ្វើឃាតនោះផងដែរ។ ការធ្វើឃាតសន្តតិជនដែលមានលំដាប់ខ្ពស់ជាង ជាអាទិ៍ ក៏ត្រូវបានបញ្ចូលជាមូលហេតុនៃអភ័ព្វបុគ្គល ព្រោះថាការធ្វើឃាតជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាងដោយជនដែលមិនត្រូវក្លាយជាសន្តតិជនសោះ ក្នុងគោលបំណងក្លាយជាមានលក្ខណសម្បត្តិជាសន្តតិជន ឬ ការធ្វើឃាតជនដែលត្រូវបានសន្មត់ថាជាសន្តតិជនដែលមានលំដាប់សន្តតិកម្មដូចគ្នា ក្នុងគោលបំណងបង្កើនចំណែកមតិក គឺជាទង្វើដែលផ្ទុយនឹងសង្គមយ៉ាងធ្ងន់ធ្ងរ។[6]

### ១.២.២ ការដឹងអំពីការសម្លាប់មតកជន តែមិនរាយការណ៍ ឬ មិនបានប្តឹង

ចំពោះការដឹង ហើយមិនរាយការណ៍អំពីការសម្លាប់មតកជន ក៏ត្រូវបានគេចាត់ទុកជាមូលហេតុនៃអភ័ព្វបុគ្គលដែរ។ បើតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការដឹងអំពីបទល្មើសណាមួយបានកើតឡើង ហើយមិនរាយការណ៍គឺត្រូវចាត់ទុកថា មានចេតនាលាក់បាំង។ វាមានភាពដូចគ្នាទៅនឹងក្រមរដ្ឋប្បវេណី គ្រង់មូលហេតុអភ័ព្វបុគ្គល ព្រោះការដឹងអំពីការសម្លាប់មតកជនហើយមិនរាយការណ៍ ឬ ប្តឹង គឺស្មើនឹងការលាក់បាំងការពិតដើម្បីបានទទួលប្រយោជន៍ណាមួយដោយសន្តតិកម្ម ឬ ពីសន្តតិជនណាម្នាក់ដែលបានប្រព្រឹត្តអំពើល្មើស។ ប៉ុន្តែ ផ្ទុយមកវិញប្រសិនណាជនដែលបានដឹងនោះ ជាជនដែលមានសតិបញ្ញាមិនគ្រប់គ្រាន់នឹងវិនិច្ឆ័យដឹងខុសត្រូវគេមិនចាត់ទុកជននោះជាអភ័ព្វបុគ្គលនោះទេ។

មួយវិញទៀត ក្នុងលក្ខខណ្ឌដែលអ្នកសម្លាប់ និងជនដែលលាក់បាំង មិនប្តឹង ឬ មិនរាយការណ៍ជាសហព័ទ្ធ ឬ ជាញាតិលោហិតខ្សែផ្ទាល់នឹងគ្នា ជននោះគេមិនចាត់ទុកជាអភ័ព្វបុគ្គលទេ ព្រោះច្បាប់បានពិចារណាទៅលើ ស្ថានភាពជាក់ស្តែង ព្រមទាំងមនោសញ្ចេតនា និងស្ថានភាពលំបាកក្នុងការប្តឹងបរិហាបទល្មើសរបស់សហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់ទៅលើជនដែលប្រព្រឹត្តបទល្មើស។ ទន្ទឹមនឹងនោះ ចំពោះការដឹងហើយមិនរាយការណ៍ មិនប្តឹងទៅលើបទល្មើស មិនមែនមាន

[6] មាត្រា ១១៥០ កថាខណ្ឌទី១ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លី ៨–៩)

ន័យថាពួកគេជាជនសមគំនិត ក្នុងការប្រព្រឹត្តបទល្មើសនោះទេ តែពួកគេជួបស្ថានភាពនោះដោយចៃដន្យ ព្រមទាំងពិបាកក្នុងការសម្រេចចិត្តថា ប្តឹង ឬ មិនប្តឹង។

***ឧទាហរណ៍៖*** *លោក **ក** បានធ្វើឃាតឪពុករបស់គាត់។ ដោយចៃដន្យ អ្នកស្រី **ខ** ដែលជាប្រពន្ធរបស់មតកជន ព្រមទាំងជាម្តាយរបស់លោក **ក** បានប្រទះឃើញសកម្មភាពនៃការធ្វើឃាតនោះ តែអ្នកស្រី **ខ** មិនបានរាយការណ៍ ឬ ប្តឹងនោះទេ។*

*សកម្មភាពរបស់ អ្នកស្រី **ខ** គឺ មិនត្រូវ បានចាត់ជាអភ័ព្វបុគ្គលនោះទេ ព្រោះត្រូវពិចារណាលើ អ្នកដែលសម្លាប់មតកជនគឺជា កូនរបស់គាត់ផ្ទាល់ ដែលស្ថិតនៅក្នុងញាតិលោហិតខ្សែផ្ទាល់។*

### ១.២.៣ ការរារាំងមតកជនធាក់ធងមតកសាសន៍

ជាទូទៅ ការធ្វើមតកសាសន៍ជាសកម្មភាពឯកតោភាគី ដែលមតកជនអាចធ្វើ អាចលុបចោល ឬ អាចកែប្រែ ដោយសេរី ទៅតាមឆន្ទៈរបស់ខ្លួនដោយមិនចាំបាច់ធ្វើការសាកសួរ ឬ យល់ព្រមពីសំណាក់ជនណាម្នាក់ឡើង។ ប៉ុន្តែក្នុងករណីដែលមានជនណាម្នាក់ក្នុងចំណោមសន្តតិជន បានប្រព្រឹត្តអំពើមិនគប្បី ដោយបានរារាំងមតកជនមិនឲ្យធ្វើ លុបចោល ឬ កែប្រែ មតកសាសន៍ ដោយអំពើនៃការឆបោកក្តី ការគម្រាមកំហែងក្តី បុគ្គលនោះត្រូវបានគេចាត់ទុកថាជាអភ័ព្វបុគ្គល។

ការរារាំងដោយ ការឆបោក ឬ ការគម្រាមកំហែង វាជាអំពើមិនត្រឹមត្រូវ ព្រោះនាំឲ្យមតកជនធ្វើនូវអ្វីដែលមិនមែនជាឆន្ទៈរបស់ខ្លួន ដោយការជឿនូវការបោកប្រាស់ ឬ ការបង្ខិតបង្ខំដោយការគម្រាម ពីជនណាម្នាក់ដែលមានប្រយោជន៍នៅក្នុងសន្តតិកម្ម ជាហេតុធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់សន្តតិជនសុចរិតផ្សេងទៀត ។

### ១.២.៤ ការគម្រាមកំហែង ឬ ឆបោកមតកជនឲ្យធ្វើ លុបចោល ឬ កែប្រែ មតកសាសន៍

ត្រង់ចំនុចនេះ គឺមិនសូវមានភាពខុសគ្នាទៅនឹងចំនុច (១.២.៣) ខាងលើនោះទេ គឺគ្រាន់តែមានភាពខុសប្លែកត្រង់ថា ចំនុចខាងលើបានសរសេរអំពីការរារាំងចំពោះការធ្វើ ការកែប្រែ ឬ លុបចោល។ រីឯចំនុចនេះវិញ គឺមិនបានរារាំងនោះទេ តែធ្វើការបង្ខិតបង្ខំ គម្រាម ឆបោក មតកជនឲ្យធ្វើ លុបចោល ឬ កែប្រែក្នុងមតកសាសន៍តែម្តង។ សកម្មភាពនេះជាអំពើស្តែងមួយ ដែលបញ្ចេញនូវគោលបំណងរបស់ជនទុច្ចរិត អោយមតកជនធ្វើទៅតាមនូវអ្វីដែលខ្លួនចង់បាន ដែលផ្ទុយទៅនឹងឆន្ទៈរបស់មតកជន។

### ១.២.៥ ក្លែងបន្លំ ឬ បំផ្លាញចោល ឬលាក់ទុកមតកសាសន៍

ជនណាប្រព្រឹត្តិអំពើក្លែងបន្លំ បំផ្លាញចោល ឬ លាក់ទុក មតកសាសន៍ ដោយមានចេតនាអាក្រក់ មិនព្រម មិនសុខចិត្ត ទៅនឹងការសម្រេចរបស់មតកជន នៅក្នុងមតកសាសន៍ជាដើម នឹងត្រូវចាត់ទុកជាអភ័ព្វបុគ្គល។ ការក្លែងបន្លំ គឺជាការផ្លាស់ប្តូរនូវ មតកសាសន៍ពិត ទៅជាមតកសាសន៍មិនពិត ដែលមានលក្ខណផ្ទុយទៅនឹងមតកសាសន៍ដើម ដែលមតកជនបានធ្វើ។ ជាមួយគ្នានោះការបំផ្លាញ គឺជាការបំបាត់ចោល ឬ បំផ្លាញចោលនូវមតកសាសន៍ពិតប្រាកដ ដើម្បីផលប្រយោជន៍ដោយឡែករបស់បុគ្គល ទៅលើសន្តតិកម្ម។ ឯការលាក់ទុកនូវលិខិតមតកសាសន៍ គឺជាការលាក់ទុកមិនព្រមបង្ហាញនូវលិខិតនោះ ដើម្បីបានប្រយោជន៍ណាមួយ។

សកម្មភាពទាំងអស់ខាងលើ សុទ្ធតែជាសកម្មភាពរបស់បុគ្គលដែលបានប្រព្រឹត្តគោលបំណងគឺដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមានចេតនាទុច្ចរិត។ ដូចនេះ ជនដែលប្រព្រឹត្តអំពើបែបនេះត្រូវសន្មត់ថាជាអភ័ព្វបុគ្គល។

## ១.៣ ជនផ្តាច់ចេញពីសន្តតិជន

នៅក្នុងមតកសាសន៍ មតកជនមានសិទ្ធិធ្វើការផ្តល់នូវមតិកឲ្យជនណាម្នាក់ក៏បាន ហើយក៏អាចផ្តាច់ជនណាម្នាក់ចេញពីសន្តតិកម្មបានដូចគ្នា។ ការផ្តាច់ចេញនេះគឺអាចធ្វើទៅបានតាមរយៈការដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មតិកពីជនណាម្នាក់ ដែលគេសន្មត់ថានឹងក្លាយទៅជាសន្តតិជនដោយមិនអោយទទួលនូវសន្តតិកម្ម ហើយចាំបាច់ត្រូវមានការពិនិត្យពីតុលាការ។ ប៉ុន្តែ មតកជនមិនអាចចេះតែកាត់ផ្តាច់ជនណាម្នាក់ចេញពីសន្តតិកម្មបានដោយចិត្តឯងនោះទេ ទាល់តែមាននូវលក្ខខណ្ឌមួយចំនួនទើបអាចកាត់ផ្តាច់បានដូចជា៖

### ១.៣.១ ធ្វើបាបមតកជន

ការធ្វើបាបមតកជន គឺមានន័យសំដៅទៅលើការ ធ្វើសកម្មភាព ដូចជាការប្រើប្រាស់អំពើហិង្សា វាយដំ ទៅលើមតកជន។ អំពើទាំងនេះត្រូវចាត់ទុកជាអំពើមិនគួរគប្បីមួយនៅក្នុងសង្គម ហើយព្រមទាំង ប្រាកចាកពីទំនៀមទម្លាប់ ប្រពៃណីជាតិ ឬ អាចហៅបានថាជាអំពើរមិលគុណ។ ការធ្វើអំពើបែបនេះ ប្រសិនបើមានលក្ខណៈធ្ងន់ធ្ងរ នោះមតកជនអាចធ្វើការអះអាងដើម្បីប្តឹងកាត់ផ្តាច់សន្តតិជនពី សន្តតិកម្ម ដោយមិនរាប់ចូលនូវបណ្តឹងព្រហ្មទណ្ឌផ្សេងទៀតនោះទេ។

### ១.៣.២ ប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ

ចំពោះការប្រមាថមតកជនវិញ គឺសំដៅទៅលើ ការប្រើពាក្យពេចន៍មិនសមរម្យទៅលើមតកជន ដូចជា ការជេរ ប្រមាថ កាតទាន មើលងាយ ប្រទិច ប្រដាស់សារ បែបណាមួយដែលមានលក្ខណ

ធ្ងន់ធ្ងរ ជាច្រើនលើកច្រើនសារ ដែលនាំអោយមតកជន មានការឈឺចិត្ត ធ្វើទុកបុកម្នេញនឹងពាក្យសំដីទាំងនោះ។

ប៉ុន្តែ មានករណីខ្លះ គឺអាស្រ័យទៅលើស្ថានភាពគ្រួសារ ក្នុងការប្រើប្រាស់នូវពាក្យសំដីដែលភាគច្រើននៅក្នុងគ្រួសារនោះ មានការប្រើប្រាស់ពាក្យមិនសមគួរជាលក្ខណៈទូទៅ នោះគេមិនត្រូវចាត់ទុកជាការប្រមាថលើមតកជននោះទេ។ ជារួម គឺអាស្រ័យទៅលើការវិនិច្ឆ័យចំពោះការប្រើប្រាស់នូវពាក្យសំដីជាប្រចាំថ្ងៃ។

### ***១.៣.៣ មានលទ្ធភាពមកមើលថែមតកជន តែមិនមក***

មួយវិញទៀត ចំពោះជនដែលនឹងក្លាយទៅជាសន្តតិជន ពុំបានមើលថែមតកជនក្នុងអំឡុងពេលមួយដែលអាចធ្វើទៅបាន ដូចជា មើលថែនាពេលមតកជនឈឺ ការមើលថែលើការហូបចុក ឬជីវភាពប្រចាំថ្ងៃ តែជននោះមិនបានធ្វើ ឬ មិនអើពើ។

*__ឧទាហរណ៍៖__ លោក **ក** មានកូន ២នាក់ **ខ** និង **គ**។ លោក **ក** បាន ឈឺធ្ងន់ ដោយ **ខ** ជាកូនដែលមានផ្ទះនៅក្បែរលោក **ក** មិនបានធ្វើការអើពើនឹងជម្ងឺលោកឡើយ ដោយខ្លួនចិញ្ចឹមចិត្តប្រចាំ ទៅលើ **គ** ដែល មានជីវភាពខ្វះព្រឹកខ្វះល្ងាច ហើយមានទីលំនៅឆ្ងាយពីលោក **ក** ៣០០ គីឡូម៉ែត។*

*ដោយឡែក ចំពោះលោក **គ** វិញ គឺមិនមែនជាជនដែលត្រូវកាត់ផ្តាច់ចេញពីមត៌កនោះទេ ទោះបីជាគាត់មិនបាន មើលថែមតកជនក៏ដោយ ព្រោះគាត់ពុំមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ការមើលថែឡើយ។*

### ***១.៣.៤ ជាប់ពន្ធនាគារមួយជីវិត***

ជនដែលជាពិរុទ្ធជន ក្នុងរឿងព្រហ្មទណ្ឌដែលបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសត្រូវជាប់ពន្ធនាគារអស់មួយជីវិត តាមរយៈបទល្មើសអ្វីក៏ដោយ ក៏មតកជនអាចធ្វើការផ្តាច់ជននោះចេញពីមតកសាសន៍បានដែរ។ បើយោងទៅតាមក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០ បុគ្គលដែលមានទោសជាប់ពន្ធនាគារមួយជីវិត ជាអភ័ព្វបុគ្គលនៃសន្តតិកម្ម។ ប៉ុន្តែ ដោយគិតឃើញថាអាចប្រើមត៌កនោះដើម្បីសងនូវការខូចខាតឲ្យជនរងគ្រោះបាន ហេតុនេះហើយបានជាក្នុងនេះ មិនចាត់ទុកថាជាអភ័ព្វបុគ្គលទេដោយឲ្យមតកជនជាអ្នកសម្រេចសេចក្តីទៅវិញ។ ត្រង់ចំនុចនេះ ឲ្យតែមតកជនបង្ហាញឆន្ទៈ

ផ្ដាច់មតិក ពីជនដែលសន្មត់ថាជាសន្តតិជនដែលត្រូវជាប់ពន្ធនាគារមួយជីវិត នោះតុលាការត្រូវទទួលស្គាល់ការសុំផ្ដាច់នោះ។[7]

### ១.៣.៥ ប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់

សកម្មភាពប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ សំដៅទៅលើសកម្មភាពណាមួយដែលត្រូវបានប្រព្រឹត្តជាលក្ខណៈច្រើនដង ហើយវាមានផលប៉ះពាល់ទៅលើផ្លូវកាយ ឬ ផ្លូវចិត្តរបស់មតកជន ឬ ទៅលើជនណាម្នាក់ដោយប្រយោល គួរឲ្យកត់សម្គាល់ ដែលជាហេតុធ្វើឲ្យមតកជនមានការចងចាំទុក។ តួយ៉ាង ដូចជាការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ដែលប្ដីបានវាយតប់ប្រពន្ធជារៀងរាល់ថ្ងៃ។ នោះមតកជន អាចកាត់ផ្ដាច់ជនដែលប្រើហិង្សាលើប្រពន្ធ (កូនប្រសារស្រីរបស់មតកជន) ចេញពីសន្តតិកម្មបាន។

ជាទូទៅ ទោះបីជាមតកជនអាចផ្ដាច់ជនដែលនឹងក្លាយទៅជាសន្តតិជន ដោយមូលហេតុខាងលើក្ដី ក៏គេនៅតែអាចធ្វើការវិនិច្ឆ័យទៅលើមតកជនផ្ទាល់ផងដែរ។ ព្រោះមានករណីខ្លះ មតកជនមានអាយុច្រើន ហើយសមត្ថភាពនៃការវិនិច្ឆ័យ ត្រូវចុះអន់ថយ ព្រមទាំងស្ថានភាពនៃមតកជនផងដែរ ដូចជាបានខឹងយ៉ាងខ្លាំងចំពោះកំហុសតូចតាច របស់ជនដែលត្រូវសន្មត់ថាជាសន្តតិជនហើយគាត់កាត់ផ្ដាច់ជននោះដោយមូលហេតុខាងលើ នោះនាំឲ្យមានភាពអយុត្តិធម៌ទៅលើជនដែលសន្មត់ជាសន្តតិជន។ ដូចនេះ ជនដែលត្រូវផ្ដាច់ចេញពីមតិក អាចធ្វើការប្ដឹងដើម្បីក្លាយទៅជាសន្តតិជនវិញបាន។[8]

### ១.៤ សន្តតិជនជាជនបរទេស

តាមរយៈច្បាប់ភូមិបាល[9] និងក្រមរដ្ឋប្បវេណីចាស់ មិនអនុញ្ញាតឲ្យជនបរទេសមានសិទ្ធិកាន់កាប់ដីធ្លី ឬ ផ្ទះដែលនៅផ្ទាល់ដីឡើយ។ យ៉ាងណាមិញបើយោងទៅ ច្បាប់ជាធរមាន[10] ក៏ដូចជាក្រមរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជា[11] មិនបានផ្ដល់សិទ្ធិឲ្យជនបរទេសមានសិទ្ធិកាន់កាប់ដីធ្លីលើទឹកដីកម្ពុជាឡើយ។

បើច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងដូច្នេះ ចុះប្រសិនបើនៅក្នុងសន្តតិកម្មមានសន្តតិជនជាជនបរទេសហើយមតិក ជាអចលនវត្ថុ ឬ ដីធ្លី។ ដូចនេះ ក្នុងករណីមានសន្តតិជនណាមួយជាជនបរទេស សន្តតិជននោះមិនអាចទទួលមតិកដែលជាដីធ្លី ដោយផ្ទាល់នោះទេ។

---

[7] មាត្រា ១១៥១ ចំនុច ឃ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃ ក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹ ៨ &៩)

[8] មាត្រា ១១៥១ វាក្យខណ្ឌទី ១ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃ ក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹ ៨ &៩)

[9] មាត្រា ៨ ច្បាប់ភូមិបាល ឆ្នាំ២០០១

[10] មាត្រា ៦ ច្បាប់ស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

[11] មាត្រា ១១៥៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជាទូទៅ ជនបរទេសក៏អាចទទួលមតិកបានដែរ លើកលែងតែមតិកជាដីធ្លី។ ប៉ុន្តែ ក្នុងករណីដែលមតកជនបានធ្វើសន្តតិកម្មជាដីធ្លី ទៅឲ្យសន្តតិជនដែលជាជនបរទេសដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ នោះដីធ្លីដែលជាមតិក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និងការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនមុនទាំងអស់នោះ។ សហសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនធ្វើការលក់ដីធ្លីនោះ ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមតិក។ ក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលសហសន្តតិជន ដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះបានយល់ព្រម ទាំងស្រុង ឬបានយល់ព្រមដោយមានកម្រិត។ តម្លៃនៃដីធ្លី ដែលបានលក់ត្រូវក្លាយទៅជាមតិក ហើយនីតិបុគ្គលនៃមតិកត្រូវរលត់។[12]

ផ្ទុយទៅវិញប្រសិនបើសហសន្តតិជននោះមិនធ្វើការលក់ដីធ្លីនោះទេ ក្នុងអំឡុងពេល ៣ខែ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ដែលមានសញ្ជាតិជាខ្មែរ។ ក្នុងករណីនេះនីតិបុគ្គលនៃមតិកដែលបានកំណត់ត្រូវចាត់ទុកថាគ្មានអត្ថិភាព។ [13]

## ២. លំដាប់នៃសន្តតិជន

សន្តតិកម្ម ត្រូវធ្វើការបែងចែកឲ្យសន្តតិជន ទៅតាមលំដាប់នៃសន្តតិជន។ អ្នកដែលមានសិទ្ធិជាសន្តតិជនទាំងអស់ មិនសុទ្ធតែបានទទួលនូវសន្តតិកម្ម ពីមតកជននោះទេ។ នោះត្រូវធ្វើការបែងចែកទៅតាមលំដាប់លំដោយនៃសន្តតិជន។ លំដាប់នៃសន្តតិជនត្រូវបានគេទទួលស្គាល់ថាជាការចាត់ថ្នាក់មួយនៃញាតិរបស់មតកជនទៅតាមច្បាប់កំណត់។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានធ្វើការបែងចែកសន្តតិជនជា៣លំដាប់ដូចជា លំដាប់ទី១ គឺ បច្ឆាញាតិផ្ទាល់ (២.១) លំដាប់ទី២ គឺជាបុព្វញាតិផ្ទាល់ (២.២) និងលំដាប់ទី៣ គឺជាសាខាញាតិ ដែលជាបងប្អូនបង្កើត (២.៣)។

### ២.១ សន្តតិជនលំដាប់ទី ១

តាមទំនៀមទម្លាប់ និងក្រមរដ្ឋប្បវេណីចាស់ និងយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា កូនរបស់មតកជនត្រូវបានចាត់ទុកជាសន្តតិជនលំដាប់ទី១[14] គឺជាអ្នកទទួលបន្តសន្តតិកម្មពីមតកជន។

កូនរបស់មតកជន មានន័យថាជាកូនដែលមានបុគ្គភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់។ ដូច្នេះ ចំពោះកូនក្រៅអាពាហ៍ពិពាហ៍ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើមិនមានការទទួលស្គាល់ទេ បុគ្គភាពតាមផ្លូវច្បាប់ក៏មិនបានកើតឡើងដែរ។ ដូចនេះ កូននោះមិន

[12] មាត្រា ១១៥៥ កថាខណ្ឌទី ៣ និង ៤ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[13] មាត្រា ១១៥៥ កថាខណ្ឌទី ៥ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[14] មាត្រា ១១៥៦ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

អាចក្លាយជាសន្តតិជនចំពោះសន្តតិកម្មរបស់ឪពុកបានឡើយ។ ម៉្យាងវិញទៀត ចំពោះកូនសុំដែលត្រូវបានបង្កើតតាម ផ្លូវច្បាប់ក៏អាចទទួលសន្តតិកម្ម ពីមតកជនដែលជាឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ។ កូនសុំ ខាងលើ សំដៅទាំងកូនសុំពេញលេញ និងកូនសុំធម្មតា។

គោលបំណងដែលគេផ្តល់អាទិភាពឲ្យកូនក្លាយជាសន្តតិជនលំដាប់ទី១ ព្រោះ៖

•កូនគឺជាសាច់ឈាមបង្កើតរបស់មតកជន ស្ថិតនៅជិតមតកជនជាងគេ

•គ្មានឪពុកម្តាយណាដាច់ចិត្ត មិនបារម្ភពីជីវភាពកូនរបស់ខ្លួននោះទេ ដោយតែងតែចង់ទុកទ្រព្យរបស់របស់ខ្លួន ដែលខិតខំសន្សំនោះ ឲ្យកូនមុនគេបង្អស់

•កូនជាអ្នកមើលថែ សុខទុក្ខ របស់ឪពុកម្តាយ

•កូនជាញាតិតែមួយគត់ដែលអាចមើលថែ ជាងញាតិដទៃបាន

ដោយមានគោលការណ៍បែបនេះហើយ ទើបច្បាប់នាពេលបច្ចុប្បន្ន បានផ្តល់សិទ្ធិក្លាយទៅជាសន្តតិជនអទិភាពដំបូង ផ្តល់ទៅឲ្យកូនរបស់មតកជន មិនថាកូនបង្កើត ឬ កូនសុំ (កូនសុំធម្មតា និងកូនសុំពេញលេញ)។

ដោយឡែក នៅពេលដែលសន្តតិជនដែលជាកូនរបស់មតកជន បានស្លាប់នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ នៅពេលដែលចាប់ផ្តើមសន្តតិកម្ម ឬជាអភ័ព្វបុគ្គល ឬ ជនដែលផ្តាច់ចេញពីមតិក កូនរបស់បុគ្គលនោះ ត្រូវក្លាយជាសន្តតិជន។ នេះគេហៅថា សន្តតិជនជំនួស។

សន្តតិជនជំនួស ធ្វើឡើងដើម្បីអោយមានភាពយុត្តិធម៌ទៅនឹងសន្តតិជនដទៃ ដែលមានលំដាប់ស្មើគ្នា។ ជារួមមក សន្តតិជនជំនួសជាបច្ឆាញាតិផ្ទាល់ក្រៅពីកូនរបស់មតកជនដូចជាចៅ ចៅទួតជាដើម។ ព្រោះចៅ ឬ ចៅទួត គឺជាញាតិលោហិតជំនាន់ក្រោយដែលមានទំនាក់ទំនងខ្សែផ្ទាល់ជាមួយនឹងមតកជន។ ត្រង់ចំនុចនេះ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន (មាត្រា ៨៨៧ កថាខណ្ឌទី២ )[15] ក៏មានគំនិតដូចគ្នាទៅនឹងក្រមរដ្ឋប្បវេណីរបស់កម្ពុជា ឆ្នាំ២០០៧ ដែរ។ ប្រសិនបើគ្មានកូនទទួលសន្តតិកម្មជំនួសទេនោះ ទ្រព្យសម្បត្តិត្រូវធ្លាក់ទៅលើសន្តតិជនដែលមានលំដាប់ស្មើ។

នៅក្នុងករណីសន្តតិកម្មជំនួស អ្វីដែលយើងគួរកត់សម្គាល់គឺ កូនបង្កើតរបស់មតកជន មានលក្ខណពិសេសត្រង់ ករណីដែលបុគ្គលទទួលសន្តតិកម្មជំនួស បានទទួលមរណភាព មុនពេលចាប់ផ្តើមសន្តតិកម្ម នោះគេអាចធ្វើសន្តតិកម្មជំនួសបន្តទៀត។ ហើយប្រសិនបើកូន និងចៅរបស់មតកជន បានទទួលមរណភាព ចៅទួតនឹងទទួលសន្តតិកម្មជំនួស។ ប្រសិនបើចៅទួតមានមូលហេតុដូចគ្នា គេអាចទទួលស្គាល់សន្តតិកម្មបន្តៗទៀតដែលគេអាចវាបានថាជាគោលការណ៍ " អនុ

[15] ម៉ាសាអូ អ៊ិកិដា, សៀវភៅណែនាំសិក្សាច្បាប់ជប៉ុន, ទំព័រ ២៦៣

វត្តជាបន្តបន្ទាប់"[16]។ ផ្ទុយមកវិញ ក្នុងករណីដែលមតកជនសុំជនដែលមានកូន តាមសុំកូនធម្មតា កូនរបស់កូនសុំធម្មតានោះ មិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ។ តែប្រសិនបើ កូនរបស់កូនសុំធម្មតានោះបានកើតក្រោយការសុំកូនវិញ កូនដែលកើតនោះ ត្រូវជាបច្ឆាញាតិផ្ទាល់របស់មតកជន ហេតុនេះហើយ អាចទទួលសន្តតិកម្មជំនួសបាន។

### ២.២ សន្តតិជនលំដាប់ទី ២

ប្រសិនបើមិនមានបច្ឆាញាតិទេនោះ នោះជនដែលក្លាយទៅជាសន្តតិជនបន្ត គឺបុព្វញាតិដូចជាឪពុកម្តាយ ជាដើម នឹងត្រូវទទួលសន្តតិកម្មបន្ត ឬ អាចហៅម៉្យាងទៀតបានថា សន្តតិជនលំដាប់ទី២។ បានជានៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គេផ្តល់អាទិភាពឲ្យបុព្វញាតិខ្សែផ្ទាល់ជាសន្តតិជន ព្រោះ៖

- បុព្វញាតិត្រូវបានគេចាត់ទុកថាជាអ្នកមានគុណ ជាអ្នកបង្កើតមតកជន
- ជាអ្នកចិញ្ចឹម បីបាច់មតកជន ព្រមទាំងផ្តល់នូវអ្វីគ្រប់យ៉ាងដល់មតកជន

ដូចនេះ នៅក្នុងស្មារតីរបស់ក្រមនេះ គឺបានផ្តល់នូវកតញ្ញូតាធម៌របស់កូនទៅលើឪពុកម្តាយ និងម៉្យាងវិញទៀត គេចាត់ទុកឪពុកម្តាយជាសាច់ញាតិដែលជិតបំផុតបន្ទាប់ពីកូនរបស់មតកជន។

មួយវិញទៀតប្រសិនបើមតកជនមានបុព្វញាតិច្រើននាក់ដូចជា ឪពុកម្តាយ ជីដូនជីតា ព្រមទាំងតាទួតយាយទួត នោះសន្តតិជនដែលមានអាទិភាពជាងគេគឺ ឪពុកម្តាយ។ ក្នុងករណីដែលឪពុករបស់មតកជនបានទទួលមរណភាព ហើយទោះបីជាជីដូនជីតាខាងឪពុកនោះនៅរស់ក៏ដោយ ប្រសិនបើម្តាយរបស់មតកជននោះនៅរស់ម្តាយនោះជាអ្នកជិតជាងគេក្នុងថ្នាក់ញាតិ ដូច្នេះ ម្តាយគឺជាសន្តតិជនលំដាប់ទី២ តែម្នាក់ឯង។ ជីដូនជីតាខាងឪពុកមិនទទួលសន្តតិកម្មជំនួសឡើយ។ ប្រសិនបើម្តាយរបស់មតកជនក៏បានទទួលមរណភាពដែរ នោះជីដូនជីតាខាងម្តាយ និងជីដូនជីតាខាងឪពុក ត្រូវទទួលសហសន្តតិកម្ម។ ប្រសិនបើជីដូនឬ ជីតាខាងម្តាយណាម្នាក់ទទួលមរណភាព បីនាក់ត្រូវទទួលសន្តតិកម្មស្មើភាគគ្នា។ ពេលធ្វើសន្តតិកម្មដោយបុព្វញាតិផ្ទាល់ គួរតែធ្វើការវិនិច្ឆ័យទៅតាមចំនួនអ្នកដែលចាំបាច់ ត្រូវមានអាហារកាតព្វកិច្ចទើបសមរម្យ ដូច្នេះមិនត្រូវធ្វើការបែងចែកចំណែកមតិកដែលត្រូវបានធ្វើសន្តតិកម្មជំនួសទេ គឺត្រូវចែកមតិកស្មើភាគគ្នាទៅតាមចំនួនមនុស្ស។

### ២.៣ សន្តតិជនលំដាប់ទី ៣

បើសិនជាពុំមានទាំងបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ ដែលជាសន្តតិជនទេ នោះបងប្អូនបង្កើតរបស់មតកជន នឹងត្រូវក្លាយទៅជាសន្តតិជន ឬ សន្តតិជនលំដាប់ទី៣ ព្រោះក្រៅពី កូន ឪពុក

[16] មាត្រា ១១៥៧ កថាខណ្ឌទី ២ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ ៦ ( គន្លឹ ៨&៩ )

ម្តាយ ជីដូនជីតា បងប្អូនបង្កើតត្រូវបានគេចាត់ទុកថាជាញាតិដែលមានឋានៈជិតជាងគេជាមួយមតកជន។ បងប្អូនបង្កើតនៅទីនេះ សំដៅទាំងបងប្អូនបង្កើតរួមឪពុកម្តាយ បងប្អូនបង្កើតរួមតែឪពុក និងបងប្អូនបង្កើតរួមតែម្តាយ ផងដែរ។

ក្នុងករណីដែលបងប្អូនបង្កើតរបស់មតកជន ជាសន្តតិជនវិញ អាចទទួលស្គាល់នូវការធ្វើសន្តតិកម្មជំនួសត្រឹមតែមួយតំណ ពោលគឺ ត្រឹមតែកូនរបស់គាត់ប៉ុណ្ណោះ[17]។ គេអាចទទួលស្គាល់សន្តតិកម្មជំនួសនោះ ដរាបណាមានបច្ចាញាតិផ្ទាល់ដែរ ក៏ប៉ុន្តែ ដោយសារសាច់ឈាមកាន់តែឆ្ងាយ ហើយមានការពិបាកនឹងរកសន្តតិជននោះផង ហេតុនេះហើយបានជាក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទទួលស្គាល់តែមួយតំណប៉ុណ្ណោះ។[18]

### ២.៤ សហព័ទ្ធ

បើយោងទៅតាមក្រមរដ្ឋប្បវេណីចាស់ របស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩២០ មិនបានឲ្យតម្លៃទៅលើសហព័ទ្ធនោះទេ ព្រោះកាលពីសម័យនោះគេមិនទាន់ឲ្យតម្លៃចំពោះការងារគេហកិច្ចរបស់ស្ត្រី ដូចទៅនឹងការងារខាងក្រៅរបស់បុរសឡើយ។ ដូចនេះហើយ គេយល់ថាស្ត្រីគ្មានសិទ្ធិទទួលចំណែកមតិកពីស្វាមីនោះទេ។ ប៉ុន្តែចំពោះក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧ បានផ្តល់អាទិភាពពេញលេញចំពោះសហព័ទ្ធ ព្រោះគេយល់ថា តម្លៃនៃការងារគេហកិច្ចស្មើនឹងតម្លៃការងារខាងក្រៅ។

មួយវិញទៀត សហព័ទ្ធត្រូវបានគេចាត់ទុកថាជាសន្តតិជនពិសេស ព្រោះដោយយោងតាមស្មារតីនៃក្រមនេះ គឺទោះបីជាមានសន្តតិជនលំដាប់ណាក៏ដោយ ក៏សហព័ទ្ធនៅតែមានសិទ្ធិក្នុងការចូលរួមនៅក្នុងសន្តតិកម្មជានិច្ច[19]។ ម្យ៉ាងវិញទៀតប្រសិនបើមានសន្តតិជនផ្សេងទៀត សហព័ទ្ធត្រូវមានឋានៈស្មើនឹងសន្តតិជនផងដែរ។

---

[17] មាត្រា ១១៥៧ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះ ៨&៩)

[18] មាត្រា ១១៦០ កថាខណ្ឌទី ៣ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះ ៨&៩)

[19] មាត្រា ១១៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

## ផ្នែកទី ២ ៖ ចំណែកមត៌ករបស់សន្តតិជន

ជាគោលការណ៍ នៅក្នុងការបែងចែកមតិកនៅប្រទេសកម្ពុជា ត្រូវបានគេកំណត់យកនូវវិធីបែងចែកមតិកជាពីរគឺ ការបែងចែកចំណែកមតិកតាមច្បាប់ (១) និងការបែងចែកចំណែកមតិកតាមឆន្ទៈរបស់មតកជន (២)។[20] ហេតុអ្វីចាំបាច់ឲ្យមានគោលការណ៍សន្តតិកម្មតាមច្បាប់? ហើយ ហេតុអ្វីចាំបាច់គោរពនូវគោលការណ៍ មានបណ្តាំរបស់មតកជន?

### ១. ចំណែកមត៌កតាមច្បាប់

ក្រោយពីមតកជនបានទទួលមរណភាព ឬ ប្រកាសពីការបាត់ខ្លួនក្នុងអំឡុងពេលណាមួយដែលច្បាប់បានកំណត់ ដោយមិនមានមតកសាសន៍ ហើយបានបន្សល់នូវ សិទ្ធិ និងករណីយកិច្ចមួយចំនួន ដែលជាសិទ្ធិបេតិកភណ្ឌ ជាហេតុនាំឲ្យមានភាពចម្រូងចម្រះក្នុងការបែងចែកទ្រព្យសម្បត្តិរវាងសន្តតិជន។ ដូច្នេះ តើនរណាជាអ្នកកំណត់ពីវិធីបែកចែក។ ដោយសារតែមានសំណួរ ចោទសួរឡើងយ៉ាងដូច្នេះហើយ ទើបនាំឲ្យក្រមរដ្ឋប្បវេណីថ្មី បានចូលខ្លួនមកធ្វើការកំណត់ពីសន្តតិជន និងការបែងចែកចំណែកមតិកចំពោះសន្តតិជន ឲ្យមានតុល្យភាពចំពោះសន្តតិជននីមួយៗ។ ចំណែកមតិកនោះមាន សន្តតិជនជាបច្ឆាញាតិផ្ទាល់ (១.១) សន្តតិជនជាបុព្វញាតិផ្ទាល់ (១.២) សន្តតិជនជាបងប្អូនបង្កើត (១.៣) និងសន្តតិជនជាសហព័ទ្ធ (១.៤)។

#### ១.១ សន្តតិជនជាបច្ឆាញាតិផ្ទាល់

ក្នុងករណី បច្ឆាញាតិផ្ទាល់គឺជាសន្តតិជនតែមួយគត់របស់មតកជន មតិកត្រូវធ្វើការបែងចែកឲ្យបច្ឆាញាតិជាកូន នូវចំណែកស្មើៗគ្នា។ ប្រសិនបើបច្ឆាញាតិដែលជាកូនរបស់មតកជនណាម្នាក់ទទួលមរណភាពមុន ឬ ស្របពេលចាប់ផ្តើមសន្តតិកម្ម នោះចំណែករបស់គេត្រូវធ្លាក់ទៅលើកូនរបស់កូននោះ (ចៅរបស់មតកជន) តាមរយៈសន្តតិជនជំនួស។ ដោយចំណែកនោះត្រូវចែកឲ្យស្មើគ្នា ទៅនឹងចំនួនសន្តតិជនជំនួស។

> ***<u>ឧទាហរណ៍៖</u>*** *លោក (ក) មានកូន២នាក់ A B។ ដោយសារតែមានជំងឺដែលមិនអាចព្យាបាលបាន លោក (ក) ក៏បានទទួលមរណភាព ដែលបានបន្សល់ទុកនូវប្រាក់នៅក្នុងធានាគារ ១០០០០ ដុល្លារ។ ជាអកុសលមិនទាន់បានធ្វើសន្តតិកម្មផង ស្រាប់តែ លោក A ដែលជាកូនច្បងជួបគ្រោះថ្នាក់ចរាចរណ៍ក៏បានស្លាប់បាត់បង់ជីវិតទៅទៀត។ តែលោក A មានកូនពីអ្នកគឺ $A_១$ និង $A_២$។ តើអ្នកណាខ្លះជាសន្តតិជន? ម្នាក់ៗទទួលបានចំណែកប៉ុន្មាន?*

[20] មាត្រា១១៩៥ កថាខណ្ឌទី ២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧




*ដូចនេះ សន្តតិជនរបស់មតកជនគឺ B និងA ជាសន្តតិជន។ តែដោយ A ស្លាប់ដូច្នេះកូនរបស់គាត់ទាំងពីរជាសន្តតិជនជំនួសគឺ A១ និងA២។*

*មតិកដែលលោក B ទទួលបានគឺ ១០០០០/២=៥០០០*

*A១ ទទួលបាន១/៤=១០០០០/៤=២៥០០*

*A២ ទទួលបាន១/៤=១០០០០/៤=២៥០០។*

### ១.២ សន្តតិជនជាបុព្វញាតិផ្ទាល់

ក្នុងករណី បុព្វញាតិផ្ទាល់ជាសន្តតិជន មតិកត្រូវធ្វើការបែងចែកទៅតាម ចំនួននៃបុព្វញាតិស្មើៗគ្នា ព្រោះបុព្វញាតិរបស់សន្តតិជនមិនសំដៅទៅលើតែឪពុកម្តាយនោះទេ។

***<u>ឧទាហរណ៍៖</u>*** *លោក **ក** គឺជាអ្នកជំនួញវ័យក្មេង គាត់មិនទាន់មានគ្រួសារទេ ប៉ុន្តែគាត់មានឪពុកម្តាយ និងជីដូនជីតាខាងឪពុក។ ជាអកុសលលោក **ក** មានគ្រោះថ្នាក់ចរាចរណ៍។ គាត់បានបន្សល់ទុកនូវទ្រព្យសម្បត្តិដូចជា ផ្ទះមួយល្វែងតម្លៃ៥០០០០ដុល្លារ លុយក្នុងធនាគារ ១០០០០ដុល្លារ។*




*→សន្តតិជនរបស់មតកជនគឺ ឪពុកម្តាយ*

*→ដូចនេះ ចំណែកមតិករបស់សន្តតិជន =៥០០០០+១០០០០= ៦០០០០ដុល្លារ*

*⇨ឪពុក និងម្តាយទទួលបាន ៦០០០០/២= ៣០០០០ដុល្លារ។*

**១.៣ សន្តតិជនជាបងប្អូនបង្កើត**

ចំណែកមតិក របស់សន្តតិជនជាបងប្អូនបង្កើតរបស់មតកជន មានការប្រែប្រួលអាស្រ័យទៅតាមប្រភេទនៃបងប្អូនបង្កើត។ បងប្អូនបង្កើត ត្រូវបានគេបែងចែកជា បងប្អូនបង្កើតរួមឪពុកម្តាយនឹងមតកជន (១.៣.១) និងបងប្អូនបង្កើតរួមតែឪពុក ឬ ម្តាយនឹងមតកជន (១.៣.២)។

***១.៣.១ បងប្អូនរួមឪពុកម្តាយ***

ក្នុងករណី បងប្អូនបង្កើតរួមឪពុកម្តាយនឹងមតកជន ជាសន្តតិជនរបស់មតកជន មតិកត្រូវធ្វើការបែងចែកស្មើៗគ្នា ទៅតាមចំនួននៃបងប្អូនបង្កើតនោះ។

***១.៣.២ បងប្អូនរួមតែឪពុក ឬ ម្តាយ***

ប៉ុន្តែផ្ទុយទៅវិញ ចំពោះបងប្អូនបង្កើតដែលរួមតែម្តាយ ឬ រួមតែឪពុកនឹងមតកជន មតិកត្រូវធ្វើការបែងចែកខុសពីបងប្អូនបង្កើត ដោយបងប្អូនដែលរួមតែឪពុក ឬ រួមតែម្តាយត្រូវទទួលចំណែកត្រឹមតែ១/២ នៃចំណែករបស់បងប្អូនដែលរួមឪពុកម្តាយ តែប៉ុណ្ណោះ។[21]

[21] មាត្រា១១៦០ វាក្យខណ្ឌទី ២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

***ឧទាហរណ៍៖*** *លោក (ក) មានបងប្អូនបង្កើតម្នាក់គឺ កញ្ញា ខ និងបងប្អូនរួមឪពុកម្នាក់គឺ លោក គ ព្រមទាំងបងប្អូនរួមម្តាយម្នាក់គឺ លោក X។ ក្រោយទទួលមរណភាព លោក (ក) បានបន្សល់ទុកនៅលុយនៅក្នុងធានាគារ១០០០០ដុល្លារ និងឡានមួយគ្រឿងតម្លៃ៣០០០០ ដុល្លារ។*

*ដោយសារតែលោក (ក) មិនមានកូន និង ឪពុកម្តាយ នាំឲ្យសន្តតិជនរបស់លោក (ក) គឺ ជាបងប្អូនបង្កើត ដូចជា កញ្ញា (ខ) លោក (គ) និង លោក (X)។*




*ដោយមតិកសរុបរបស់លោក ក ដែលជាមតកជនសរុបទាំងអស់ ៤០០០០ដុល្លារ*

*⇨ដូចនេះ កញ្ញា ខ ទទួលបានសន្តតិកម្ម ២០០០០ដុល្លារ*

*⇨លោក គ ជាបងប្អូនបង្កើតរួមឪពុក នាំឲ្យ លោក គ ទទួលបានមតិក១/២នៃមតិករបស់ ខ ដែលជាបងប្អូនបង្កើត ស្មើនឹង ២៥០០ដុល្លារ។*

*⇨លោក X ជាបងប្អូនបង្កើតរួមម្តាយ នាំឲ្យ លោក X ទទួលបានមតិក ១/២ នៃមតិករបស់ ខ ដែលជាបងប្អូនបង្កើត ស្មើនឹង ២៥០០ដុល្លារ។*

### ១.៤ សន្តតិជនជាសហព័ទ្ធ

ដោយយោងទៅតាមការបកស្រាយខាងលើ (២.៤) សហព័ទ្ធជាសន្តតិជនជានិច្ច ដែលត្រូវមានលំដាប់ស្មើនឹងសន្តតិជនផ្សេងទៀត ប៉ុន្តែ ប្រសិនបើមានតែសហព័ទ្ធតែឯង នោះចំណែកមតិកទាំងអស់ត្រូវធ្លាក់ទៅលើសហព័ទ្ធ។

ក្នុងករណីដែលមានសន្តតិជនផ្សេងទៀត នោះចំណែកមតិករបស់សហព័ទ្ធ នឹងមានការប្រែប្រួល ទៅតាមប្រភេទនៃសន្តតិជន ដូចជា សន្តតិជនជាបច្ឆាញាតិ (១.៤.១) សន្តតិជនជាបុព្វញាតិផ្ទាល់ (១.៤.២) និងសន្តតិជនជាបងប្អូនបង្កើត (១.៤.៣) ។

### ១.៤.១ សហព័ទ្ធ និងបច្ឆាញាតិ

ក្នុងករណីសហព័ទ្ធ និង កូនបង្កើតជាសន្តតិជន នោះក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានផ្តល់អាទិភាព ឲ្យសហព័ទ្ធ និងកូនបង្កើត មានចំណែកមត៌កស្មើៗគ្នា។ ការកំណត់ឲ្យសហព័ទ្ធ និងកូនទាំងអស់មានចំណែកស្មើគ្នានេះ គឺដោយសារតែគិតពិចារណាទៅដល់ការចំណាយសម្រាប់ការរស់នៅ ជាអាទិ៍ ក្រោយពេលដែលមតកជនបានទទួលមរណភាព។

*__ឧទាហរណ៍៖__ លោក **ក** និងកញ្ញា **ខ** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។ ហើយ ពួកគាត់មានកូន ៣ នាក់ **គ , ឃ , ង**។ លោក **ក** បានទទួលមរណភាព ហើយបានបន្សល់ទុកនូវទ្រព្យសម្បត្តិមួយចំនួន។ តើសន្តតិជននីមួយៗទទួលបានចំណែកប៉ុន្មាន?*

*សន្តតិជនរបស់លោក **ក** គឺ កូន ទាំង ៣ របស់គាត់ **គ, ឃ,ង** និងសហព័ទ្ធរបស់គាត់ លោកស្រី **ខ**។*

*ដូច្នេះមត៌កដែលត្រូវទទួលបានគឺ **គ=ឃ=ង=ខ** = ១/៤ ក្នុងម្នាក់ៗ។*

### ១.៤.២ សហព័ទ្ធ និងបុព្វញាតិ

បុព្វញាតិរបស់មតកជនត្រូវបានគេសំដៅទៅលើ ឪពុកម្តាយ ព្រមទាំង ជីដូនជីតា របស់មតកជន។ ដូចនេះ ក្នុងករណីដែលមតកជនមានឪពុកម្តាយ និងសហព័ទ្ធ ដែលជាសន្តតិជន ចំណែកមត៌កត្រូវធ្វើការបែងចែកជាពីរភាគគឺ សហព័ទ្ធត្រូវទទួលបាន១/៣ រីឯ ឪពុកម្តាយត្រូវទទួល ២/៣នៃចំណែកមត៌កទាំងមូល។ ប៉ុន្តែបើ ឪពុកឬ ម្តាយរបស់មតកជន នៅរស់តែម្នាក់ ឪពុកម្តាយនោះ និងសហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា។[22] មួយវិញទៀតប្រសិនបើ មតកជនមានឪពុកម្តាយលើសពីពីរនាក់ នោះចំណែកមត៌ក ២/៣ របស់ឪពុកម្តាយ ត្រូវធ្វើការបែងចែកទៅតាមចំនួនបុព្វញាតិនោះ។ ប៉ុន្តែ ផ្ទុយមកវិញ ប្រសិនបើមតកជនមានបុព្វញាតិក្រៅពី ឪពុកម្តាយ ដែលជាសន្តតិជន នោះសហព័ទ្ធ នឹងទទួលចំណែកមត៌ក ១/២ ហើយសហសន្តតិជនដែលជាបុព្វញាតិក្រៅពីឪពុកម្តាយក៏ត្រូវទទួលចំណែក ១/២ ហើយត្រូវចែកចំណែក១/២នោះ ទៅតាមចំនួនសហសន្តតិជន។

[22] មាត្រា ១១៦២ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.៣ សហព័ទ្ធ និងបងប្អូនបង្កើត

ក្នុងករណីសហព័ទ្ធ និងបងប្អូនបង្កើតរបស់មតកជន ជាសន្តតិជន។ សហព័ទ្ធត្រូវទទួលបាន១/២ នៃចំណែកមតិកទាំងអស់ រីឯចំណែកមតិកដែលនៅសល់១/២ទៀតត្រូវធ្លាក់ទៅលើសហសន្តតិជនដទៃទៀតដែលជាបងប្អូនបង្កើតដោយធ្វើការបែងចែកស្មើៗគ្នា។[23]

## ២.ចំណែកមត៌ករបស់សន្តតិជនក្នុងករណីមានបណ្តាំ

ការបែកចែកមតិកករណីមានបណ្តាំ វាមានភាពងាយស្រួលចំពោះសន្តតិជន ព្រោះមតកជនបានធ្វើការបែងចែកចំណែកឲ្យសន្តតិជនម្នាក់ៗរួចទៅហើយនៅក្នុងបណ្តាំមតកសាសន៍។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការបែងចែកមតិកជាពីរប្រភេទគឺ ចំណែកមតិកដែលបានកំណត់ដោយមតិកសាសន៍(២.១) និងការកំណត់វិធីបែងចែកដែលសន្មត់ថាជាចំណែកមតិក (២.២)។

### ២.១ ការកំណត់ចំណែកមត៌ក

ការកំណត់ចំណែកមតិកគឺជា ការផ្លាស់ប្តូរភាគនៃចំណែកសន្តតិកម្មតាមច្បាប់។ មតកជនអាចកំណត់ចំណែកមតិករបស់សន្តតិជន តាមមតកសាសន៍ដោយឆន្ទៈផ្ទាល់ខ្លួនបាន។ ចំណែកមតិកនៃសន្តតិជនដែលមតកជនបានកំណត់ហៅថា ចំណែកមតិកតាមការកំណត់។ ប៉ុន្តែមិនត្រូវបំពានលើភាគបម្រុងដែលច្បាប់បានកំណត់ចំពោះសន្តតិជនផ្សេងទៀតឡើយ។ នៅក្នុងករណីដែលការកំណត់ចំណែកមតិកបំពានភាគបម្រុង ត្រូវអនុឡោមតាមបទបញ្ញត្តិស្តីពីភាគបម្រុង។ ការកំណត់ចំណែកមតិក មានច្រើនវិធីដូចជា វិធីកំណត់តាមសមាមាត្រ (២.១.១) វិធីកំណត់នូវទ្រព្យជាក់ស្តែង (២.១.២) និងវិធីកំណត់ចំណែកមតិកសម្រាប់សហសន្តតិជនផ្សេងទៀត (២.១.៣)។

#### *២.១.១ វិធីកំណត់តាមសមាមាត្រ*

វិធីកំណត់ជាសមាមាត្រ គឺជាការកំណត់ចំណែកមតិកជាភាគទៅឲ្យសន្តតិជន។ មតកជនអាចកំណត់ចំណែកមតិកទៅឲ្យសន្តតិជនណាម្នាក់មានភាគច្រើនជាងគេ ឬ អាចកំណត់ជាភាគដូចទៅនឹងសន្តតិកម្មតាមច្បាប់ក៏បាន។

*__ឧទាហរណ៍៖__ ករណីជនដែលត្រូវសន្មត់ថាជា សន្តតិជនគឺជា ប្រពន្ធ និងកូន ២នាក់ នោះបើគិតតាមចំណែកមតិកតាមផ្លូវច្បាប់គឺ សន្តតិជនត្រូវបាន ១ភាគ៣ ម្នាក់ ក៏ប៉ុន្តែ មតកជនអាចកំណត់ក្នុងមតកសាសន៍ឲ្យនរណាម្នាក់ ក្នុងចំណោមអ្នកទាំងនោះទទួលចំណែក ១ ភាគ ២ បាន។*

[23] មាត្រា ១១៦២ វាក្យខណ្ឌទី ៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.១.២ វិធីកំណត់នូវទ្រព្យជាក់ស្តែង

វិធីកំណត់នូវទ្រព្យជាក់ស្តែង គឺជាការបែងចែកមតិកទៅឲ្យសន្តតិជន ដោយកំណត់នូវទ្រព្យសម្បត្តិណាមួយជាក់លាក់ជាពិសេស ដូចជា ដី ផ្ទះ ឬ រថយន្ត។

*__ឧទាហរណ៍៖__ មតកជន **ក** មានកូនពីរនាក់គឺ X និង Y គាត់បានបន្សល់មតិកដែលជាដីនៅខេត្តកំពង់ចាម មួយកន្លែងមានតម្លៃ ៤៥០០ដុល្លារ និង ផ្ទះមួយល្វែងនៅភ្នំពេញ មានតម្លៃ ៥៥០០ដុល្លារ ដែលគិតជាប្រាក់សរុប ១០០០០ដុល្លារ។ មុនគាត់ទទួលមរណភាព គាត់បានធ្វើមតកសាសន៍ដោយឲ្យ X ស្នងដីនៅខេត្តកំពង់ចាម និង Y ស្នងផ្ទះនៅភ្នំពេញ។*

### ២.១.៣ វិធីកំណត់ចំណែកមត៌កសម្រាប់សហសន្តតិជនផ្សេងទៀត

វិធីកំណត់ចំណែកមតិកសហសន្តតិជនផ្សេងទៀត គឺអាចធ្វើបានក្នុងករណីដែលមតកជនបានធ្វើការកំណត់ចំណែកមតិកសម្រាប់សហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់។

*__ឧទាហរណ៍៖__ សន្តតិជនមានបីនាក់គឺ **ក ខ គ** រីឯមតិកមាន១០០០ដុល្លារ។ ហើយ **ក** បានទទួលផលប្រយោជន៍ពិសេសចំនួន៥០០ដុល្លារ ហើយមតកជនបានកំណត់ចែកមតិកឲ្យ **ខ** ៨០០ដុល្លារ។ ក្នុងករណីនេះទ្រព្យដែលបានចាត់ទុកថាជាមតិកគឺ ១៥០០ដុល្លារ (១០០០+៥០០) ហើយចំណែកមតិកគឺ ១៥០០÷៣=៥០០ដុល្លារ។ ហេតុដូច្នេះភាគដែលត្រូវបានចាត់ទុកថាជាចំណែកមតិករបស់ **ក** និង **ខ** គឺ ០ រីឯ **គ** និងបាន ៥០០ដុល្លារ (នេះក៏ព្រោះថា **ក** បានទទួលផលប្រយោជន៍ពិសេសចំនួន ៥០០ដុល្លារ រួចទៅហើយ ហើយ **ខ** និងបានទទួលចំណែកមតិកតាមការកំណត់ចំនួន ៨០០ដុល្លារ)។ ក៏ប៉ុន្តែ ទ្រព្យដែលនៅសល់ក្រោយពីដកចំណែកដែលកំណត់សម្រាប់ **ខ** នោះមានតែ ២០០ដុល្លារ ទេ ហេតុនេះហើយ **គ** បានទទួលមតិកជាក់ស្តែងតែ ២០០ដុល្លារ ប៉ុណ្ណោះ។*

## ២.២ ការកំណត់វិធីបែងចែក

នៅក្នុងមតកសាសន៍ មតកជនអាចធ្វើការកំណត់វិធីបែងចែកមតិកដោយផ្ទាល់បាន។ ប៉ុន្តែមុននឹងឈានទៅដល់ការកំណត់វិធីបែងចែកបាន ត្រូវដឹងអំពី បុគ្គលដែលអាចកំណត់វិធីបែងចែក

(២.២.១) កម្មវត្ថុ (២.២.២) លក្ខខណ្ឌដែលអាចហាមឃាត់មិនឲ្យបែងចែកមតិកក្នុងអំឡុងពេល(២.២.៣) និងវិធីបែងចែកមតិក (២.២.៤)។

### ***២.២.១ បុគ្គលដែលអាចកំណត់វិធីបែងចែក***

បុគ្គលដែលអាចកំណត់វិធីបែងចែកបានគឺ មតកជន ព្រោះមតកជនជាម្ចាស់នៃទ្រព្យសម្បត្តិ គាត់មានសិទ្ធិអាចធ្វើការកំណត់នូវវិធីបែងចែកតាមរយៈមតកសាសន៍ (២.២.១.១)។ ប៉ុន្តែមតកជនដែលជាម្ចាស់បណ្តាំក៏អាចធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឲ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះតាមមតកសាសន៍បាន (២.២.១.២)។

#### ***២.២.១.១ ការកំណត់នូវវិធីបែងចែកដោយមតកជនផ្ទាល់***

មតកជនជាអ្នកធ្វើការកំណត់នូវវិធីបែងចែកមតិក ដែលអាចធ្វើតាមរយៈមតកសាសន៍ ដែលធ្វើការកំណត់ចំពោះសន្តតិជនច្រើននាក់ ឬ សន្តតិជនតែម្នាក់។

> ***<u>ឧទាហរណ៍៖</u>*** *មតកជនអាចកំណត់ឲ្យកូនរបស់គាត់ឈ្មោះ **ក** ទទួលមតិកជាដីមួយកន្លែងនៅខេត្តកំពង់ចាម ឲ្យកូនឈ្មោះ **ខ** ទទួលមតិកជាផ្ទះមួយល្វែងនៅភ្នំពេញ និងធ្វើការបែងចែកឲ្យកូនឈ្មោះ **គ** ទទួលបានមតិកជាប្រាក់នៅក្នុងធនាគារ។*

#### ***២.២.១.២ ការប្រគល់អាណត្តិឲ្យតតិយជន***

ក្នុងករណីដែលមតកជនមិនអាចធ្វើការបែងចែកទ្រព្យសម្បត្តិដោយផ្ទាល់នោះទេ គាត់អាចប្រគល់អាណត្តិទៅឲ្យតតិយជនកំណត់នូវការបែងចែកនេះបាន។ ដូចជាប្រគល់អាណត្តិឲ្យទៅឪពុកបង្កើតរបស់មតកជនក្នុងការកំណត់នូវវិធីបែងចែកមតិក។[24]

ផ្ទុយទៅវិញ មតកជនអាចចាត់តាំងសន្តតិជនណាម្នាក់ ឲ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍។ ជាពិសេស ក្នុងករណីដែលបានធ្វើមតកសាសន៍ជាការកំណត់សន្តតិជនណាម្នាក់ទទួលសន្តតិកម្មនូវ មតិកទាំងអស់ ហើយព្រមជាមួយគ្នានេះ ចាត់តាំងអ្នកនោះធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ ជាភាពងាយស្រួលមួយ។

ម្យ៉ាងទៀត ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅសន្តតិជន ដោយគ្មានការយឺតយ៉ាវ។ ម្យ៉ាងទៀត ប្រសិនបើម្ចាស់បណ្តាំមិនបានហាមទេ ជនដែលបានទទួលអាណត្តិនេះ អាចកំណត់យកខ្លួនឯងធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បាន។

[24] មាត្រា ១១៨៣ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះ ៨&៩)

ទោះបីជាបានទទួលអាណត្តិពីម្ចាស់បណ្តាំឲ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ក៏ដោយ ក៏មិនមែនបានសេចក្តីថា ជនដែលបានទទួលអាណត្តិនោះ មានករណីយកិច្ចត្រូវតែទទួលមុខងារនេះដោយស្វ័យប្រវត្តិដែរ ពោលគឺជននោះអាចបដិសេធមិនទទួលអាណត្តិបាន។ ក៏ប៉ុន្តែក្នុងករណីដែលម្ចាស់បណ្តាំ បានប្រគល់អាណត្តិតតិយជនឲ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ប្រសិនបើតតិយជននោះមិនបានលុបចោលនូវអាណត្តិនេះវិញទេ មិនអាចយកនីតិវិធីណាមួយដើម្បីធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ហេតុនេះហើយ ប្រសិនបើជនដែលបានទទួលអាណត្តិនោះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះទៅសន្តតិជនដោយគ្មានការយឺតយ៉ាវ។ ម្យ៉ាងទៀត ក្នុងករណីដែលជនដែលបានទទួលអាណត្តិមិនបានធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងមិនបង្ហាញឆន្ទៈលាឈប់ពីអាណត្តិនេះទេ នីតិវិធីនៃការដាស់តឿននឹងត្រូវបានធ្វើឡើង។

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និងជនក្ស័យធន មិនអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ។

### ២.២.២ កម្មវត្ថុ

ចំពោះកម្មវត្ថុ នៅក្នុងការកំណត់វិធីបែងចែក ដែលមតកជនបានកំណត់នៅក្នុងមតកសាសន៍ មតកជនអាចបែងចែកឲ្យ សហសន្តតិជនស្នង ជាដី ជាប្រាក់ ទៅតាមចិត្តរបស់មតកជន ដោយឲ្យមានភាពប្រហាក់ប្រហែលទៅតាមចំណែកមត៌កដែលកំណត់ដោយច្បាប់។ ប៉ុន្តែ ការកំណត់ដោយច្បាប់គឺ សហសន្តតិជន ទទួលបាននូវចំណែកមត៌កស្មើៗគ្នា។ ផ្ទុយមកវិញ ចំពោះការកំណត់វិធីបែងចែករបស់មតកជន គឺអាចនឹងមានភាពលំអៀង ព្រោះមតកជនបានកំណត់ឲ្យសហសន្តតិជននីមួយៗស្នងនូវកម្មវត្ថុដែលខ្លួនបានឲ្យទៅតាមបំណង ការចូលចិត្តរបស់ខ្លួនទៅលើសន្តតិជនតែប៉ុណ្ណោះ។

*__ឧទាហរណ៍៖__ លោក **ក** មានកូន ៣ នាក់ A B និងC ដោយមុនមរណភាព លោក **ក** បានធ្វើការកំណត់នៅក្នុងបណ្តាំមត៌ក ឲ្យ សហសន្តតិជននីមួយៗទទួលបាន៖ A ត្រូវស្នង ដី មួយកន្លែង,B ស្នង ផ្ទះ និង C ទទួលសន្តតិកម្មទ្រព្យដែលនៅសល់ ។ ប៉ុន្តែដោយសារតែ ដី ដែល A បាន ស្នងមានតំលៃ ១០០០០ដុល្លារ, ផ្ទះរបស់ B បានស្នង មានតំលៃ ១៥០០០ដុល្លារ រីឯ C ស្នងសន្តតិកម្មទ្រព្យដែលនៅសល់ដែលមានតំលៃស្មើ ៨០០០ដុល្លារ។*

- *បើគិតតាមសន្តតិកម្មតាមច្បាប់វិញ គឺសហសន្តតិជន ម្នាក់ៗទទួលបាន ១ ភាគ ៣។ ប៉ុន្តែដោយសារតែ គិតទៅតាមការកំណត់វិធីបែងចែក ទៅតាមបណ្តាំមត៌ករបស់មតកជន គឺសហសន្តតិជនត្រូវបាននូវចំណែកដែលមត៌កផ្តល់ឲ្យ។*

### ២.២.៣ លក្ខខណ្ឌ

បើទោះបីជា នៅក្នុងបណ្តាំមតិក មតកជនបានធ្វើការកំណត់នូវវិធីបែងចែករួចទៅហើយក្តីក៏មតកជនអាចធ្វើញ្ញត្តិកម្ម ហាមឃាត់មិនឲ្យសហសន្តតិជនធ្វើការបែងចែកចំណែកមតិកភ្លាមៗបានដែរ។ តួយ៉ាងដូចជា ការហាមឃាត់មិនទាន់ឲ្យបែងចែកមតិកក្នុងករណីដែរ មតកជនចង់ការពារកូនមួយចំនួនដែលមិនទាន់គ្រប់អាយុជានីតិជន ជាដើម។

ចំពោះអំឡុងពេលដែលហាមឃាត់ គឺអាចកំណត់មិនលើសពី ៥ឆ្នាំ ដែលគិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម[25] (ដោយយោងតាមវាក្យខណ្ឌទី២ កថាខណ្ឌទី ១ នៃមាត្រា ២១១ ស្តីពីការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ)[26]។ ក្នុងការហាមឃាត់នេះ គឺអាចបន្តបានជាថ្មីបាន មុនអំឡុងពេល ៥ឆ្នាំដោយតតិយជន (២.១.១.២)[27]។ ទោះបីជាមានការហាមឃាត់ បែបនេះក៏ដោយ ក៏សហសន្តតិជន នៅតែមានសិទ្ធិក្នុងប្រើប្រាស់ អាស្រ័យផលទៅលើទ្រព្យដែលជា ចំណែករបស់សហសន្តតិជននីមួយៗ។

### ២.២.៤ វិធីបែងចែកមតិក

ការកំណត់នូវវិធីបែងចែកមតិក គឺជាការសម្រេចថា ត្រូវផ្តល់ប្រភេទទ្រព្យសម្បត្តិបែបណាទៅឲ្យសន្តតិជនមួយណា។ វិធីបែងចែកមតិកមានច្រើនវិធី ដូចជា ការបែងចែកមតិកជាវត្ថុជាក់ស្តែង (២.២.៤.១) ការបែងចែកមតិកជាតម្លៃថ្នូរ (២.២.៤.២) និងការបែងចែកមតិកដោយការប្តូរជាប្រាក់ (២.២.៤.៣)។

#### ២.២.៤.១ ការបែងចែកមតិកជាវត្ថុជាក់ស្តែង

ការបែងចែកវត្ថុជាក់ស្តែង គឺជាវិធីធ្វើការបែងចែកវត្ថុដោយផ្ទាល់តែម្តង ដោយមតកជន។[28]

*__ឧទាហរណ៍៖__ មតកជន **ក** មានកូន ៣នាក់ **ខ គ** និង **ឃ** ហើយមានមតិកដែលជា ផ្ទះ ៥០០០ ដុល្លារ រថយន្ត ១០០០ ដុល្លារ និងសាច់ប្រាក់ ៩០០០ ដុល្លារ។ ក្នុងករណីមតកជន **ក** បានបន្សល់ទុកមតកសាសន៍ដែលមានខ្លឹមសារថា "ឲ្យផ្ទះទៅកូន **ខ** ឲ្យរថយន្ត និងសាច់ប្រាក់ ៤០០០ ដុល្លារ ទៅឲ្យកូន **គ** និងឲ្យសាច់ប្រាក់ ៥០០០ ដុល្លារទៅឲ្យ **ឃ** ។" នោះកូន **ខ** កូន **គ** និង កូន **ឃ** ត្រូវបែងចែកមតិកដូចខ្លឹមសារមតកសាសន៍របស់មតកជន **ក** ។*

[25] មាត្រា ១១៨៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[26] មាត្រា ១១៨៣ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹ ៨&៩)

[27] មាត្រា ២១១ វាក្យខណ្ឌទី ២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[28] ក្រមរដ្ឋប្បវេណី ភាគ ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២ ), ទំព័រ ៣៥

### ២.២.៤.២ ការបែងចែកមត៌កជាតម្លៃថ្នូរ

ការបែងចែកមតិកជាតម្លៃថ្នូរ គឺជាវិធីធ្វើការបែងចែកមតិកដោយឲ្យសន្តតិជនណាម្នាក់ទទួលទ្រព្យមួយទាំងមូល ហើយបង់ជាថ្លៃថ្នូរសមស្រប ទៅតាមចំណែកមតិកនៃសន្តតិជនម្នាក់ៗទៅឲ្យសហសន្តតិជនទាំងនោះ។[29]

***ឧទាហរណ៍៖*** *លោក **ក** មានកូន២នាក់ គឺលោក **A** និងលោក **B**។ លោក **A** រៀបអាពាហ៍ពិពាហ៍ហើយក៏បានបែកផ្ទះមករស់នៅខាងក្រៅ។ មុនពេលដែលលោក **ក** ទទួលមរណភាព គាត់បានធ្វើបណ្តាំមតិកប្រគល់ផ្ទះទាំងមូលឲ្យទៅ **B** ប៉ុន្តែ **B** ត្រូវប្រគល់លុយឲ្យទៅ **A** ចំនួន៥០០០០ដុល្លារ។ ចំនួនទឹកប្រាក់ ៥០០០០ដុល្លារ ដែល **B** ត្រូវប្រគល់ឲ្យ **A** គឺជាថ្នូរដែល **B** អាចទទួលបានផ្ទះទាំងមូល។*

### ២.២.៤.៣ ការបែងចែកមត៌កដោយការប្តូរជាប្រាក់

មួយវិញទៀត ការបែងចែកមតិកដោយការប្តូរជាប្រាក់ គឺជាវិធីធ្វើការបែងចែកមតិកតាមរយៈការបែងចែកថ្លៃលក់ដែលបានមកពីការលក់ដោយបង្ខំ។[30]

***ឧទាហរណ៍៖*** *មុនពេលទទួលមរណភាពមតកជនបានបន្សល់ទុកនូវទ្រព្យសម្បត្តិមួយចំនួនដូចជា ម៉ូតូមួយគ្រឿង ដីមួយកន្លែង ផ្ទះមួយខ្នង។ សហសន្តតិជនទាំងអស់អាចប្រើប្រាស់នូវវិធីមួយដែលងាយស្រួលដល់ការបែងចែកចំណែកមតិក គឺធ្វើការលក់នូវមតិកទាំងអស់នោះ ហើយធ្វើការបែងចែកនូវប្រាក់នោះស្មើៗគ្នា។*

ទន្ទឹមនឹងនោះ មតកជនអាចធ្វើការកំណត់ចំណែកមតិក និងកំណត់វិធីបែងចែកមតិក ក្នុងពេលព្រមគ្នាបាន។

[29] ក្រមរដ្ឋប្បវេណី ភាគ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២), ទំព័រ ៣៥

[30] ក្រមរដ្ឋប្បវេណី ភាគ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២), ទំព័រ ៣៥

## ជំពូកទី ២៖ ការសម្រួលចំណែកមត៌ក

ប្រសិនបើសន្តតិជនណាម្នាក់ ក្នុងចំណោមសហសន្តតិជនបានទទួលនូវទ្រព្យសម្បត្តិពីមតកជនកាលនៅរស់ ហើយធ្វើការបែងចែកមតិកតាមសន្តតិកម្មដោយទទួលបានចំណែកស្មើគ្នានឹងសន្តតិជនផ្សេងទៀត នោះសន្តតិជនដែលទទួលបានទ្រព្យពីមតកជនកាលនៅរស់ នឹងទទួលបាននូវចំណែកច្រើនជាងគេមិនខានឡើយ។ ការទទួលបានច្រើនជាងគេនេះ នឹងធ្វើឲ្យមិនមានភាពស្មើគ្នារវាងសន្តតិជន។ ហេតុដូចនេះហើយ ការសម្រួលនូវចំណែកមតិករវាងសហសន្តតិជនគួរគប្បីយកមកពិចារណា ក្នុងគោលបំណងដើម្បីឲ្យសន្តតិជនទទួលបាននូវចំណែកមតិកស្មើៗគ្នា។

ហេតុដែលនាំឲ្យមានការសម្រួលចំណែកមតិកនោះគឺ ករណីមានការទទួលនូវផលប្រយោជន៍ពិសេស (ផ្នែកទី ១) និងភាគនៃវិភាគទាន (ផ្នែកទី ២)។

### ផ្នែកទី ១៖ ផលប្រយោជន៍ពិសេស

ដើម្បីស្វែងយល់នូវផលប្រយោជន៍ពិសេសឲ្យបានច្បាស់លាស់ នោះត្រូវសិក្សាអំពី សញ្ញាណនៃផលប្រយោជន៍ពិសេស (១) តម្លៃនៃផលប្រយោជន៍ពិសេស(២) និងវិធីនៃការសម្រួលចំណែកមតិក (៣) ក្នុងករណីមានផលប្រយោជន៍ពិសេស។

#### ១. សញ្ញាណនៃផលប្រយោជន៍ពិសេស

ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា១១៦៣ បានកំណត់អំពីអត្ថន័យនៃផលប្រយោជន៍ពិសេសថាគឺជាប្រទានកម្មពិសេសនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជន ពោលគឺ ផលប្រយោជន៍ពិសេសគឺជាប្រទានកម្មពិសេស ឬ អច្ច័យទាន។ ផលប្រយោជន៍ពិសេស គឺជាប្រទានកម្មពិសេសដែលមតកជនបានផ្តល់នូវទ្រព្យណាមួយទៅឲ្យសន្តតិជន[31]។

កាលណា សន្តតិជនណាម្នាក់ទទួលបាននូវផលប្រយោជន៍ពិសេស ហើយបន្តទទួលបាននូវចំណែកមតិកស្មើនឹងសន្តតិជនផ្សេង នោះវានឹងមិនមានតុល្យភាពរវាងសហសន្តតិជនឡើយ។ ដោយនៅក្នុងនោះសន្តតិជនដែលទទួលបាននូវផលប្រយោជន៍ពិសេស នឹងទទួលបាននូវមតិកច្រើនជាងគេជាក់ជាមិនខានឡើយ។

---

[31] ក្រមរដ្ឋប្បវេណី ភាគ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២ ), ទំព័រ ៣២

*__ឧទាហរណ៍៖__ លោក A បានទទួលមរណៈភាព ដោយលោកគ្មានភរិយានោះទេ។ ប៉ុន្តែលោកមាន កូន ៣ នាក់ គឺ X, Y,និង Z ។ លោកបានបន្សល់ទុកនូវមតិកចំនួន ១២០០ ដុល្លារ។ ប៉ុន្តែកាលពីលោក A នៅរស់ គាត់បានផ្តល់ផលប្រយោជន៍ពិសេស ឲ្យទៅលោក X នូវទឹកប្រាក់ចំនួន ៣០០ ដុល្លារ។*

*ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើគ្មានការសម្រួលចំណែកមតិកទេនោះ ការទទួលមតិកនឹងមានស្ថានភាពដូចខាងក្រោម៖*

*មតិកមាន ១២០០ ដុល្លារ ហើយសន្តតិជនមានចំនួន ៣ នាក់ គឺ X, Y,និង Z ។ ហើយសន្តតិជនម្នាក់ៗត្រូវទទួលបានចំណែកគ្នា។ មានន័យថា នៅពេលចាប់ផ្តើមសន្តតិកម្ម X, Y,និង Z នឹងទទួលបានមតិកម្នាក់ ៤០០ ដុល្លារ ( ១២០០/៣)។ កុំភ្លេចថា នៅមុនពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជន X បានទទួលប្រាក់ ៣០០ ដុល្លាររួចហើយ។ ដូចនេះបើគ្មានការសម្រួលចំណែកមតិកទេ ក្នុងសន្តតិកម្មរបស់លោក A នោះសន្តតិជន X ទទួលបាន ៧០០ ដុល្លារ ចំណែកឯសន្តតិជន Y និង Z ទទួលបានតែ ៤០០ ដុល្លារ ប៉ុណ្ណោះ។ បញ្ហានេះហើយដែលនាំឲ្យគ្មានតុល្យភាពរវាងសន្តតិជន។*

*ក្នុងគោលគំនិតដើម្បីដោះស្រាយ នូវបញ្ហាគ្មានតុល្យភាពខាងលើនេះ ទើបក្រមរដ្ឋប្បវេណីកម្ពុជាបានបញ្ញត្តិនូវការសម្រួលចំណែកមតិក ក្នុងករណីមានផលប្រយោជន៍ពិសេសណាមួយ ចំពោះសន្តតិជន តាមរយៈមាត្រា ១១៦៣ ។*

តាមមាត្រា ១១៦៣ ដែលបានផ្តល់និយមន័យនៃផលប្រយោជន៍ពិសេស ការទទួលបាននូវទ្រព្យសម្បត្តិពីមតកជន ត្រូវចាត់ថាទុកជាផលប្រយោជន៍ពិសេស លុះត្រាតែជា ប្រទានកម្មបូករួមផ្សំនឹងឱកាសពិសេស(១.១) ប្រទានកម្មដើម្បីមូលធនសម្រាប់ជីវភាពរស់នៅ (១.២) និងប្រទានកម្មដែលផ្តល់ឲ្យសន្តតិជនតាមរយៈមតកសាសន៍ (១.៣)។

### ១.១ ប្រទានកម្មក្នុងឱកាសពិសេស

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាមួយដែលមានអានុភាពដោយភាគីម្ខាង បង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃហើយភាគីម្ខាងទៀតយល់ព្រមទទួល[32]។ ប្រទានកម្មមិនមែនជាសកម្មភាពឯកតោភាគីនោះទេ ហើយមានគោលគំនិត គឺមិនយកកម្រៃតប

[32] មាត្រា ៥៦៨ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ស្នង។ ប្រទានកម្មអាចប្រព្រឹត្តទៅបានគ្រប់កាលៈទេសៈ ឲ្យតែមានអ្នកឲ្យ និងអ្នកទទួល។ ប៉ុន្តែ ប្រទានកម្មដែលគួរឲ្យកត់សម្គាល់ជាងគេ គឺប្រទានកម្មដែលពាក់ព័ន្ធក្នុងសន្តតិកម្ម។

ប្រទានកម្មដែលពាក់ព័ន្ធក្នុងសន្តតិកម្ម គឺធ្វើឡើងដោយមតកជន ផ្តល់នូវអ្វីមួយដែលមានតម្លៃទៅឲ្យជនដែលសន្មត់ថាជាសន្តតិជន។ ប៉ុន្តែ ប្រទានកម្មមុនពេលទទួលមរណភាពរបស់មតកជន មិនមែនជាផលប្រយោជន៍ពិសេសគ្រប់ករណីនោះទេ[33]។ ប្រសិនបើ ប្រទានកម្មដែលមិនធ្វើឡើងក្នុងឱកាសពិសេស (អាពាហ៍ពិពាហ៍ ជាដើម) ឬ មិនមែនសម្រាប់មូលធននៃជីវភាពទេ មិនត្រូវបានវិនិច្ឆ័យថាជាផលប្រយោជន៍ពិសេសឡើយ។ ដូច្នេះ ប្រទានកម្មដែលត្រូវបានវិនិច្ឆ័យថាជាផលប្រយោជន៍ពិសេស គឺជាប្រទានកម្មដែលធ្វើឡើងក្នុងឱកាសពិសេស ឬ មូលធនសម្រាប់ជីវភាពរស់នៅ និងប្រទានកម្មតាមមតកសាសន៍ (អច្ច័យទាន)។

ប្រទានកម្មដែលពាក់ព័ន្ធក្នុងសន្តតិកម្ម គឺជាប្រទានកម្មនៅក្នុងឱកាសពិសេសណាមួយ។ ឱកាសពិសេស គឺជាពិធីអ្វីមួយដែលមានលក្ខណៈធំដុំ និងកើតមានយូរៗម្តង។ ដោយយោងទៅតាមក្រមរដ្ឋប្បវេណី គេចាត់ទុកផលប្រយោជន៍ពិសេស គឺជាប្រទានកម្មនៅក្នុងឱកាសពិសេសមានដូចជា អាពាហ៍ពិពាហ៍ (១.១.១) និងប្រទានកម្មក្នុងហេតុការណ៍ផ្សេងៗ (១.២.២)។

### ***១.១.១ អាពាហ៍ពិពាហ៍***

អាពាហ៍ពិពាហ៍ គឺជាពិធីមួយសំរាប់មនុស្សពីរនាក់ ដោយមានការរៀបចំឡើងធំជាងពិធីផ្សេងៗ ព្រមទាំងមានញាតិ មិត្ត ចូលរួម។ ប្រសិនបើសន្តតិជនជាបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍ ហើយបានទទួលនូវប្រទានកម្មពីមតកជន ក្នុងឱកាសអាពាហ៍ពិពាហ៍របស់ខ្លួន នោះត្រូវចាត់ទុកជាផលប្រយោជន៍ពិសេស។

ប៉ុន្តែមានចំនុចមួយដែលគួរត្រូវពិចារណានោះគឺ ប្រសិនបើមតកជនផ្តល់ឲ្យសន្តតិជនត្រឹមតែកម្រិតនៃចំណងដៃ នាឱកាសអាពាហ៍ពិពាហ៍ នោះប្រហែលជាមិនត្រូវបានទទួលស្គាល់ជាផលប្រយោជន៍ពិសេសនោះទេ។

| |
|---|
| ***<u>ឧទាហរណ៍៖</u>*** *នៅពេលរៀបអាពាហ៍ពិពាហ៍ មតកជនបានចងដៃ សន្តតិជននូវ ផ្ទះមួយល្វែងដែលមានតម្លៃ ប្រហែលជា ២០០០០ដុល្លារ ។*<br><br>*តើនេះអាចចាត់ទុកជាផលប្រយោជន៍ពិសេសដែរ រឺ ទេ ប្រសិនបើមតិកចងដៃក្នុងឱកាសអាពាហ៍ពិពាហ៍បែបនេះ?* |

[33] ក្រមរដ្ឋប្បវេណី ភាគ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២ ), ទំព័រ ៣២

*ជាទូទៅ ប្រសិនបើ មតកជនចងដៃសន្តតិជនក្នុងឱកាសអាពាហ៍ពិពាហ៍ ព្រមទាំងផ្ទះមួយល្វែង នោះអាចចាត់ទុកជាផលប្រយោជន៍ពិសេស។ ប៉ុន្តែចំណុចនេះក៏ត្រូវពិចារណាទៅលើមុខរបររបស់មតកជនផងដែរះ*

*•មតកជនជាសេដ្ឋី មានប្រាក់ពាន់លានដុល្លារ នោះកម្រិតដែលបានឲ្យទៅសន្តតិជនគេអាចចាត់ទុកថាមិនមែនជាផលប្រយោជន៍ពិសេសនោះទេ ព្រោះគេអាចបកស្រាយបានថាវាជាប្រាក់ចំនួនតិចតួច។*

*•ប៉ុន្តែ ប្រសិនបើមតកជនជាអ្នករកស៊ីធម្មតា នោះគេចាត់ទុកថា វាជាផលប្រយោជន៍ពិសេសព្រោះតម្លៃផ្ទះមួយល្វែងជាចំនួនច្រើន។*

### ១.១.២ ហេតុការណ៍ផ្សេងៗ

ហេតុការណ៍ផ្សេងទៀត នៅក្នុងមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី ត្រូវបានគេបកស្រាយថាហេតុការណ៍ដែល មានលក្ខណៈប្រហាក់ប្រហែលនឹងអាពាហ៍ពិពាហ៍ ដូចជា ពិធីខួបកំណើត ពិធីឡើងផ្ទះ ពិធីបង្កក់កូនជាដើម...។ល។ ដូចនេះប្រទានកម្មដែលមតកជនធ្វើចំពោះសន្តតិជនត្រូវបានបកស្រាយថា ជាផលប្រយោជន៍ពិសេស លើកលែងតែក្នុងកម្រិតនៃចំណងដៃ។

ប្រសិនបើ ការចងដៃជាកម្រិតទូទៅ ដូចជាប្រាក់ ឬ វត្ថុអនុស្សាវរីទ៍ទូទៅ នោះមិនមែនជាផលប្រយោជន៍ពិសេសនោះទេ។ ម្យ៉ាងវិញទៀត ប្រទានកម្មក្នុងពិធីកំជាប់ពាក្យ តើអាចចាត់ទុកថាជាផលប្រយោជន៍ពិសេសដែរ រឺទេ? បើយោងទៅតាមទំនៀមទម្លាប់ ប្រពៃណីខ្មែរ ត្រូវបានគេទទួលស្គាល់ថាបុរសត្រូវចូលដណ្តឹងស្ត្រី ព្រមទាំងមានជាប់ទាំងជំនួន ថ្លៃបណ្តាការ (ថ្លៃផ្ទះ ឬ ថ្លៃទឹកដោះ)។ នោះនាំឲ្យ អាចពិចារណាបានថា វាអាចជាផលប្រយោជន៍ពិសេស ព្រោះប្រទេសកម្ពុជាបានឲ្យតម្លៃបណ្តាការ ថាជាចំនួនប្រាក់មួយដែលច្រើនលើសពីទំហំធម្មតា។ តួយ៉ាង ប្រសិនបើគ្រួសារមួយមានកូនស្រី ៣នាក់ កូនប្រុស ១នាក់ ហើយម្តាយចូលដណ្តឹងកូនស្រីគេអោយទៅកូនប្រុស នោះក្នុងករណីនេះ អាចចាត់ទុកបានថាជាផលប្រយោជន៍ពិសេស ព្រោះកូនស្រីទាំង ៣នាក់ មិនត្រូវចំណាយលើការស្តីដណ្តឹង ប៉ុន្តែ កូនប្រុសបែរជាត្រូវចំណាយប្រាក់ស្តីដណ្តឹងកូនស្រីគេ។

***<u>ឧទាហរណ៍៖</u>*** *មតកជនផ្តល់នូវ កាដូរឲ្យសន្តតិជនក្នុងពិធីខួបកំណើត។*

### ១.២ មូលធននៃជីវភាពរស់នៅ

មូលធននៃជីវភាពរស់នៅ គឺជាការផ្តល់នូវទ្រព្យសម្បត្តិ ការផ្តល់ឲ្យនូវការរស់នៅដែលល្អជាងគេ។ តួយ៉ាង ជាទូទៅឪពុកម្តាយ មានកាតព្វកិច្ចផ្តល់អាហារកិច្ចចំពោះកូនគ្រប់ៗគ្នា។ ប៉ុន្តែនៅពេលដែលឪពុកម្តាយផ្តល់ឲ្យកូនណាម្នាក់ នូវការផ្គត់ផ្គង់ដែលមានលក្ខខណ្ឌពិសេសជាងគេ នោះវាមិនស្មើគ្នាទេ ក្នុងការទទួលបាននូវសេចក្តីស្រឡាញ់ និងអាហារកិច្ច។ ដូចនេះ ការធ្វើបែបនេះ វាហាក់ដូចជាមានភាពអយុត្តិធម៌សម្រាប់កូនផ្សេងទៀត។ នោះចំណែកពិសេសជាងគេ គួរតែអាចចាត់ទុកថាជា ការទទួលនូវផលប្រយោជន៍ពិសេស។

ទន្ទឹមនឹងនោះ ផលប្រយោជន៍ពិសេសក្នុងឱកាសមូលធននៃជីវភាពរស់នៅ មិនមែនជាការផ្តល់ឲ្យក្នុងទំហំបន្តិចបន្តួច សម្រាប់ចាយវាយប្រចាំថ្ងៃ រួចហៅថាផលប្រយោជន៍ពិសេសនោះទេ[34]។ ផ្ទុយទៅវិញ បើការផ្តល់ឲ្យនោះ លើសពីទំហំធម្មតា នោះត្រូវចាត់ទុកថាជាផលប្រយោជន៍ពិសេស។

ប៉ុន្តែ មានសំណួរមួយលើកឡើងថា តើកម្រិតនៃទ្រព្យសម្បត្តិ ប៉ុន្មានត្រូវចាត់ទុកជាផលប្រយោជន៍ពិសេស?

ដោយយោងតាមការអនុវត្តន៍នៅជប៉ុន កត្តាដ៏សំខាន់មួយក្នុងចំណោមកត្តាដ៏សំខាន់ជាច្រើន នៅក្នុងការបកស្រាយបញ្ហានេះ គឺចំនួនទឹកប្រាក់នៃអំណោយ មានន័យថា ទឹកប្រាក់កាន់តែធំ រឹតតែអាចចាត់ទុកជាផលប្រយោជន៍ពិសេស យើងត្រូវពិនិត្យទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់មតកជន[35]។

*__ឧទាហរណ៍៖__ មតកជនមានទ្រព្យសម្បត្តិ ១លាន ដុល្លារ ដោយឲ្យ ១០០ ដុល្លារ ទៅសន្តតិជន នេះហាក់ដូចជាមិនមែនជាផលប្រយោជន៍ពិសេសនោះទេ ព្រោះគេអាចចាត់ទុកថា វាជាចំនួនតិចតួចណាស់។*

*•ការឲ្យដីធ្លី ហាក់ដូចជាផលប្រយោជន៍ពិសេស*

*•ការឲ្យប្រាក់ទិញផ្ទះ ហាក់ដូចជាផលប្រយោជន៍ពិសេស*

*•កំជាប់ពាក្យ ការលើកជំនូន អាច ឬមិនអាចចាត់ទុកជាផលប្រយោជន៍ពិសេស អាស្រ័យទៅលើការចំណាយ និន្នាការ ប្រពៃណី ជាអាទិ៍ នៅក្នុងសាសនា។*

មួយវិញទៀត ទោះបីជានៅក្រមរដ្ឋប្បវេណីបានចែងអត្ថន័យនៃផលប្រយោជន៍ពិសេសបែបនេះក្តី ប៉ុន្តែមិនមានមាត្រា ឬ សេចក្តីពន្យល់ណាមួយ ដែលកំណត់អំពីអត្ថន័យនៃផលប្រយោជន៍

[34] ក្រមរដ្ឋប្បវេណី ភាគ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២ ), ទំព័រ ៣២
[35] ក្រមរដ្ឋប្បវេណី ភាគ៦ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២ ), ទំព័រ ៣៣

ពិសេសឲ្យបានច្បាស់លាស់នោះទេ។ ប៉ុន្តែផ្ទុយទៅវិញ មានការបកស្រាយពីសំណាក់អ្នកច្បាប់ ដូចជា ចៅក្រម មេធាវី សាស្រ្តាចារ្យច្បាប់ ជាដើម...។..។ ទន្ទឹមនឹងនោះ មានពេលខ្លះគេបានបកស្រាយ អំពីផលប្រយោជនពិសេសប្រៀបធៀបនឹងរបបនៃអាហារកិច្ចថា ប្រសិនការផ្តល់ឲ្យទៅសន្តតិជនណា ម្នាក់លើសពីកម្រិតនៃអាហារកិច្ចនោះនឹងត្រូវចាត់ទុកថាជាប្រយោជន៍ពិសេស។

*__ឧទាហរណ៍៖__ មតកជន X មានកូន ៤ នាក់ គឺ A B C និងD។ មតកជន បានបញ្ជូន A ឲ្យទៅបន្តការសិក្សានៅក្រៅប្រទេស ដោយចំណាយអស់ ៣០០០០ ដុល្លារ ។ ប៉ុន្តែចំណែកឯកូន ៣នាក់ទៀត B C និង D គឺឲ្យបន្តការសិក្សាត្រឹមតែក្នុងស្រុកតែប៉ុណ្ណោះ។*

*ដូចនេះ មតកជន X បានផ្តល់នូវមូលធនជីវភាពរស់នៅឲ្យកូន A ល្អជាងគេ។ ចំណែកឯកូន A ដែលបានបន្តការសិក្សានៅឯបរទេស ត្រូវចាត់ទុកថាបានទទួលផលប្រយោជន៍ពិសេស។*

### ១.៣ អច្ច័យទាន

អច្ច័យទាន គឺជាប្រទានកម្មទ្រព្យសម្បត្តិតាមរយៈមតកសាសន៍របស់មតកជន។ ការកំណត់ចំណែកមតិក និងការកំណត់វិធីបែងចែកចំណែកមតិក ជាកម្មវត្ថុចំពោះតែសន្តតិជនប៉ុណ្ណោះ ប៉ុន្តែ អច្ច័យទាន អាចជាកម្មវត្ថុចំពោះតតិយជនក្រៅពីសន្តតិជនបាន។

ជាក់ស្តែង អច្ច័យទានគឺជាផលប្រយោជន៍ពិសេសរៀងរាល់ពេល[36] ឬ អច្ច័យទានជាប្រទានកម្ម ដែលមតកជនធ្វើឡើងតាមរយៈមតកសាសន៍។ ដូចនេះ ប្រទានកម្មចំពោះសន្តតិជនតាមរយៈមតកសាសន៍ នោះត្រូវទទួលស្គាល់ថាជាផលប្រយោជន៍ពិសេស។

## ២. តម្លៃនៃផលប្រយោជន៍ពិសេស

បន្ទាប់ពី មតកជនបានផ្តល់ឲ្យសន្តតិជននូវផលប្រយោជន៍ពិសេស នោះការចាត់ចែងរាល់ផលប្រយោជន៍ពិសេសដែលសន្តតិជនបានទទួល គឺជាសិទ្ធិរបស់សន្តតិជន។ ប៉ុន្តែក្នុងករណីនេះ អាចមានចំណោទបញ្ហាចោទឡើងថា ប្រសិនបើ តម្លៃនៃផលប្រយោជន៍ពិសេសមានការប្រែប្រួល មានការផ្លាស់តាមរយៈការចាត់ចែងដោយសន្តតិជនដែលបានទទួល មុនពេលចាប់ផ្តើមសន្តតិកម្ម តើតម្លៃនៃផលប្រយោជន៍ពិសេសនោះ ត្រូវកំណត់យកតម្លៃមួយណា? តម្លៃនៅពេលដែលបានទទួលផលប្រយោជន៍ពិសេស ឬ តម្លៃនៅពេលចាត់ចែង? គួរសម្គាល់ថា តម្លៃនៃផលប្រយោជន៍ពិសេស

[36] ក្រមរដ្ឋប្បវេណី ភាគ៦, ទំព័រ៣២ ( បោះពុម្ពក្នុងខែ មីនា ឆ្នាំ ២០១២ ) , ទំព័រ៣២

អាចប្រែប្រួលទៅតាមរយៈពេល។ ដូចនេះ ប្រសិនបើមានករណីបាត់បង់ ឬ វិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម (២.១) ឬ តម្លៃនៃប្រទានកម្មមានការផ្លាស់ប្តូរ ដូចជាករណីកើនឡើងនៃតម្លៃប្រទានកម្ម (២.២) តើយកតម្លៃណាមួយ ធ្វើជាកម្មវត្ថុក្នុងការសម្រួលចំណែកមតិក?

### ២.១ ករណីបាត់បង់ ឬ វិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម

ប្រសិនបើ អ្នកដែលទទួលបានផលប្រយោជន៍បានចាត់ចែងទ្រព្យដែលបានទទួលដោយប្រទានកម្មមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ ក្នុងករណីដែលទ្រព្យសម្បត្តិនោះត្រូវបានបាត់បង់ ឬ វិនាសមុនពេលចាប់ផ្តើមសន្តតិកម្មដោយឯកឯង នោះតម្លៃផលប្រយោជន៍ពិសេសត្រូវគណនាដោយយកតាមតម្លៃនៅពេលចាត់ចែង ឬ នៅពេលបាត់បង់នោះ[37]។

**សម្គាល់៖** ត្រង់ចំនុចនេះ គេការពារសន្តតិជនដែលទទួលបានផលប្រយោជន៍ពិសេសដែលបានដឹងហើយថាតម្លៃនៃផលប្រយោជន៍ពិសេសនោះ ទុកយូរថ្ងៃកាន់តែទាបទៅៗ ដូចជា តម្លៃនៃចលនវត្ថុជាដើម។

ប៉ុន្តែ ប្រសិនបើអ្នកដែលទទួលបានផលប្រយោជន៍ពិសេស ជាអ្នកចាត់ចែងនូវផលប្រយោជន៍ពិសេសនោះ ធ្វើឲ្យមានការបាត់បង់ ឬ វិនាសនូវតម្លៃប្រទានកម្ម ឬ មានការផ្លាស់ប្តូរនូវទ្រព្យសម្បត្តិមួយផ្នែកណាមួយ នោះតម្លៃនៃផលប្រយោជន៍ពិសេសត្រូវគណនាដោយចាត់ទុកថាមានស្ថានភាពដើម។ ពោល គឺតម្លៃនៅពេលចាប់ផ្តើម ឬ ទទួលបានផលប្រយោជន៍ពិសេស។

***<u>ឧទាហរណ៍៖</u>*** *មតកជនបានឲ្យរថយន្តមួយគ្រឿង តម្លៃ ១០០០០ ដុល្លារ ទៅ សន្តតិជន។ ក្រោយមកតម្លៃរថយន្តនោះធ្លាក់ថ្លៃសល់ ៥០០០ ដុល្លារ នៅពេលចាប់ផ្តើមសន្តតិកម្ម។ ដូចនេះ នៅពេលចាប់ផ្តើមសន្តតិកម្ម គេត្រូវគណនាចូលមតិក ត្រឹមកម្រិតដែលនៅសល់តែប៉ុណ្ណោះ។*

### ២.២ ករណី កើនឡើងនៃតម្លៃប្រទានកម្ម

ក្នុងករណីតម្លៃនៃប្រទានកម្មកើនឡើង ក៏មានភាពដូចគ្នាទៅនឹងថយចុះដែរ ក៏ប៉ុន្តែតម្លៃនៃប្រទានកម្មកើនឡើងមានគោលគំនិតផ្ទុយទៅនឹង តម្លៃនៃប្រទានកម្មថយចុះ។ ប្រសិនបើតម្លៃនៃផលប្រយោជន៍ពិសេសនោះ បានកើនឡើង បានប្រាក់ការ ឬ ផលចំណេញ ដោយឯកឯង នោះគេគណនាតម្លៃនៃប្រទានកម្មនោះដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម។

[37] មាត្រា ១១៦៤ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប៉ុន្តែផ្ទុយមកវិញ ក្នុងករណីដែល អ្នកដែលទទួលបានផលប្រយោជន៍ពិសេស បានធ្វើការកើនតម្លៃនៃប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសនោះ ដោយខ្លួនឯងផ្ទាល់ នោះតម្លៃដែលត្រូវគណនាចូលជាមត៌ក ត្រឹមកម្រិតតម្លៃនៃស្ថានភាពដើមដែរ។ ត្រង់ចំនុចនេះ វាមានគោលគំនិតផ្ទុយគ្នា ដែលពេលតម្លៃនៃប្រទានកម្មថយចុះដោយអ្នកទទួលបានផលប្រយោជន៍ពិសេស ត្រូវគិតតម្លៃនៅពេលបាត់បង់ និងពេលកើនឡើង នោះផលប្រយោជន៍ពិសេសត្រូវគិតតម្លៃនៅពេលដូចស្ថានភាពដើមពេលមត៌កជនផ្តល់ឲ្យ។

**សម្គាល់៖** ចំនុចនេះមានការការពារនូវផលចំណេញ ដែលអ្នកទទួលបានផលប្រយោជន៍ពិសេសព្យាយាមរក្សាការពារ យូរថ្ងៃ ខែ ឆ្នាំ ខិតខំបង្កើនទ្រព្យ ដូចជា អចលនវត្ថុ ដី ផ្ទះ ....។

ម្យ៉ាងវិញទៀត ប្រសិនបើតម្លៃនៃផលប្រយោជន៍ពិសេស ឬ តម្លៃនៃប្រទានកម្ម ឬ តម្លៃរូបិយវត្ថុអាចមានការផ្លាស់ប្តូរ នោះមិនមានចែងនូវវិធីគណនា ក្នុងករណីនេះទេ។[38] ចំនុចនេះមិនមែនជាបញ្ហាដែលពាក់ព័ន្ធទៅនឹងសន្តតិកម្មនោះទេ គឺវាអាចទាក់ទងនឹងបញ្ហាផ្សេងទៀត។ ដូច្នេះត្រូវអាស្រ័យទៅលើការបកស្រាយ។ សម្រាប់ករណីប្រទេសជប៉ុន តម្លៃនៃកម្មវត្ថុដែលបានទទួលដោយប្រទានកម្ម មានការផ្លាស់ប្តូរ មតិភាគច្រើនអះអាងត្រូវគណនាទៅតាមតម្លៃដែលមាន នៅពេលចាប់ផ្តើមសន្តតិកម្ម។ ម្យ៉ាងវិញទៀត ដោយយោងតាមសាលដីកានៃតុលាការកំពូលជប៉ុន ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៦ ប្រទានកម្មជាប្រាក់ ត្រូវគណនាដោយប្តូរតម្លៃប្រាក់នៅពេលទទួលប្រទានកម្មនោះ ទៅតាមតម្លៃរូបិយវត្ថុពេលចាប់ផ្តើមសន្តតិកម្ម។[39]

*<u>**ឧទាហរណ៍៖**</u> មត៌កជនបានប្រគល់ ដី មួយកន្លែង មានតម្លៃ ២០០០០ ដុល្លារ ក្នុងឆ្នាំ ២០០១។ មកដល់ថ្ងៃចាប់ផ្តើមសន្តតិកម្ម ឆ្នាំ ២០០៥ តម្លៃដីនោះឡើងដល់ ៥០០០០ ដុល្លារ។ ដូចនេះ តម្លៃនៃផលចំណេញពី ដី ៣០០០០ ដុល្លារ គេមិនគិតគណនាចូលមត៌កសរុបនោះទេ។*

### ៣. វិធីនៃការសម្រួលចំណែកមត៌ក

វិធីនៃការសម្រួលចំណែកមត៌ក ធ្វើឡើងក្នុងគោលបំណង សម្រួលមត៌កចំពោះសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេស ដើម្បីធ្វើឲ្យមានសមភាពត្រឹមត្រូវជាក់ស្តែងរវាងសហសន្តតិជនដែលមិនបានទទួលបានផលប្រយោជន៍ពិសេស។

[38] មាត្រា១១៦៤ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះទី ៨ –ទី ៩)
[39] មាត្រា១១៦៤ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះទី ៨ –ទី ៩)

### ៣.១ តម្លៃនៃមត៌កក្នុងករណីមានផលប្រយោជន៍ពិសេស

ក្នុងករណីដែលក្នុងចំណោមសហសន្តតិជនទាំងអស់ ប្រសិនបើមានបុគ្គលណាម្នាក់ដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវិតរស់នៅ ឬ បានទទួលអច្ច័យទានពីមតកជន ហើយប្រសិនបើមានការទទួលស្គាល់ថាជាផលប្រយោជន៍ពិសេស ក្នុងសន្តតិកម្ម តើតម្លៃនៃមតិកសរុបត្រូវធ្វើការគណនាយ៉ាងដូចម្តេច?

តម្លៃមតិកសរុបត្រូវគណនាដូចខាងក្រោម៖

តម្លៃមតិកដែលមាននាពេលចាប់ផ្តើមសន្តតិកម្ម + បូកបញ្ចូលតម្លៃនៃប្រទានកម្មដែលជាផលប្រយោជន៍ពិសេស

*__ឧទាហរណ៍៖__ មតកជន Y មានកូនពីរនាក់ A និង B ។ A បានទទួលផលប្រយោជន៍ពិសេសពី Y នូវប្រាក់ចំនួន ៥០០០ ដុល្លារ។ ទ្រព្យសម្បត្តិដែលបានបន្សល់នៅពេលទទួលមរណភាពមានប្រាក់ ១០០០០ ដុល្លារ។*

*ដូចនេះតម្លៃមតិកសរុប គឺ ៥០០០ដុល្លារ +១០០០០ដុល្លារ= ១៥០០០ ដុល្លារ។*

### ៣.២ ចំណែកមត៌ករបស់សន្តតិជនក្នុងករណីមានផលប្រយោជន៍ពិសេស

ជាទូទៅ ប្រសិនបើមតិកដែលមតកជនបានបន្សល់ត្រឹមកម្រិតដែលមានជាក់ស្តែង មិនថាដោយមានបណ្តាំក្តី ឥតបណ្តាំក្តី នោះមិនមែនជាបញ្ហាចោទសម្រាប់សន្តតិជនក្នុងរឿងតុល្យភាពនៃចំណែកទ្រព្យសម្បត្តិនោះទេ។ ប៉ុន្តែប្រសិនបើមានមតិកអរូបី ដូចជាផលប្រយោជន៍ពិសេសចូលមកនោះ ចំណែកមតិកនឹងមានភាពស្មុគស្មាញក្នុងការបែងចែក។ ករណីមានផលប្រយោជន៍ពិសេសអាចមាន ករណីទូទៅ (៣.២.១) និង ករណីតម្លៃនៃផលប្រយោជន៍ពិសេសលើសពីចំណែកមតិក (៣.២.២)។

#### *៣.២.១ ករណីទូទៅ*

នៅក្នុងសិទ្ធិទទួលសន្តិកម្មរបស់សន្តិជននីមួយៗ គឺមានសិទ្ធិទទួលបាននូវចំណែកស្មើៗគ្នា។ ប៉ុន្តែ ក្នុងករណីដែលមានសន្តតិជនណាម្នាក់ បានទទួលនូវផលប្រយោជន៍ពិសេស ហើយផលប្រយោជន៍ពិសេសនោះតិចជាង ឬ ស្មើតម្លៃនៃចំណែកមតិកនៃសហសន្តតិជន នោះចំណែកមតិករបស់សន្តតិជនត្រូវគណនាដូចខាងក្រោម៖

- ករណីមានសន្តតិជនទទួលបានផលប្រយោជន៍ពិសេស

–ប្រសិនបើផលប្រយោជន៍ពិសេស < (តិចជាង) សិទ្ធដែលបានទទួល ⇨ មតិកដែលសន្តតិជនទទួលបាន = ចំណែកសិទ្ធិដែលនៅសល់

ចំណែកមតិកសន្តតិជននីមួយៗ (ជាក់ស្តែង)=

(សិទ្ធិដែលបានទទួល ឬ នៅសល់÷សិទ្ធិសរុបរបស់សន្តតិជន) × មតិកចាប់ផ្តើមសន្តតិកម្ម

### ៣.២.២ ក្នុងករណីតម្លៃនៃផលប្រយោជន៍ពិសេសលើសពីចំណែកមត៌ក

ក្នុងករណីដែលមតកជនទទួលបាននូវផលប្រយោជន៍ពិសេស លើសពីចំណែកមតិក នោះសន្តតិជនពុំចាំបាច់បង្វិលទ្រព្យដែលទាក់ទងនឹងចំណែកលើសនោះមកវិញនោះទេ[40]។

ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលលើសពីតម្លៃនៃចំណែកមតិក សហសន្តតិជនពុំចាំបាច់បង្វិលមកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្មដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។[41] មួយវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណីចាស់នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៦០០ បានចែងថាប្រសិនបើចំណែកមតិកតិចជាងតម្លៃទ្រព្យដែលបង្វិលទៅវិញ ត្រូវបង្វិលសងវិញនូវចំនួនដែលខ្វះ។ ប៉ុន្តែ មាត្រា ១១៦៥ បានជ្រើសរើសយកគោលនយោបាយនីតិកម្មផ្ទុយពីនេះ។ ចំពោះការបង្វិលនូវចំណែកលើស ត្រូវប្រគល់ទៅឲ្យរបបកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដោះស្រាយ ដោយគោរពតាមឆន្ទៈរបស់មតកជនកាលនៅរស់ ឬ ឆន្ទៈរបស់សន្តតិជន។[42]

ប៉ុន្តែមានក្រមមួយចំនួនបានចែងពីចំនុចនេះ ដូចជាក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២០៥៦ បានចែងថា ពុំចាំបាច់បង្វិលភាគលើសវិញដែរ។ ប៉ុន្តែ ប្រសិនបើ មិនបង្វិលនូវភាគលើសវិញនោះទេ តើចំណែកមតិករបស់សហសន្តតិជនត្រូវគណនាយ៉ាងដូចម្តេច?

- ករណីមានសន្តតិជនទទួលបានផលប្រយោជន៍ពិសេស

–ប្រសិនបើផលប្រយោជន៍ពិសេស ≥ (ធំជាង រឺស្មើ) សិទ្ធដែលបានទទួល ⇨ មតិកដែលសន្តតិជនទទួលបាន = 0 (សូន្យ)

***<u>ឧទាហរណ៍៖</u>*** *មតកជន Z មានកូន ៤ នាក់គឺ A B C និង D ។ មុនចាប់ផ្តើមធ្វើសន្តតិកម្ម Z បាន ឲ្យប្រាក់ទៅ A ចំនួន ១០០០០ ដុល្លារ, B បានទទួល ៨០០០ ដុល្លារ និង C បានទទួល ១០០០ដុល្លារ ។ ក្នុងពេលចាប់ផ្តើមសន្តតិកម្ម មតកជន Z មានមតិក ៥០០០ ដុល្លារ។*

[40] មាត្រា ១១៦៥ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះទី ៨ –ទី ៩)

[41] មាត្រា ១១៦៥ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[42] មាត្រា១១៦៥ កថាខណ្ឌទី ១ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះទី ៨ –ទី ៩)

តាមការគណនា

មត៌កសរុប = ៥០០០+១០០០០+៨០០០+១០០០= ២៤០០០ ដុល្លារ

ប្រសិនបើគិតទៅតាមច្បាប់ គឺ សន្តតិជននីមួយៗទទួលបាន ១ ភាគ ៤ ក្នុងម្នាក់ៗ

→ចំណែកមត៌ករបស់សន្តតិជនម្នាក់ៗ= ២៤០០០÷៤= ៦០០០ ដុល្លារ ក្នុងម្នាក់ៗ ។

ប៉ុន្តែដោយសារតែមានសន្តតិជន ៣ នាក់ទទួលបានផលប្រយោជន៍ពិសេស

→ A ទទួលបាន ១០០០០ ដុល្លារ ⇨ ១០០០០ > ៦០០០ ⇨ ចំណែកដែល A ត្រូវទទួលបាន ស្មើ 0

→ B ទទួលបាន ៨០០០ ដុល្លារ ⇨៨០០០ > ៦០០០⇨ ចំណែកដែល B ត្រូវទទួលបាន ស្មើ 0

→ C ទទួលបាន ១០០០ ដុល្លារ ⇨ ១០០០ < ៦០០០⇨ ចំណែកដែល C ត្រូវទទួលបាន ស្មើ នឹង ៦០០០ –១០០០= ៥០០០ ដុល្លារ

→ D ទទួលបាន 0 ដុល្លារ ⇨ 0 < ៦០០០⇨ ចំណែកដែល D ត្រូវទទួលបាន ស្មើ នឹង ៦០០០ –0= ៦០០០ ដុល្លារ

ប៉ុន្តែត្រូវគណនាតាមចំណែកមត៌ករបស់សន្តតិជននីមួយៗ តាមការជាក់ស្តែង គឺ៖

(សិទ្ធិដែលបានទទួល ឬ នៅសល់÷សិទ្ធិសរុបរបស់សន្តតិជន) × មត៌កចាប់ផ្តើមសន្តតិកម្ម

ដោយ សិទ្ធិដែលនៅសល់ របស់ C = ៥០០០ ដុល្លារ , D = ៦០០០ ដុល្លារ

សិទ្ធិនៅសល់សរុប = ៥០០០+៦០០០= ១១០០០ដុល្លារ

មត៌កចាប់ផ្តើមសន្តតិកម្ម = ៥០០០ ដុល្លារ

⇨C= (៥០០០÷១១០០០)×៥០០០= ២២៧២ ដុល្លារ

⇨D = (៦០០០÷១១០០០)×៥០០០= ២៧២៧ ដុល្លារ

ដូចនេះអ្នកដែលទទួលមត៌កដែលនៅសល់មានតែ C និង D តែប៉ុណ្ណោះគឺ C ទទួលបាន។

## ផ្នែកទី២៖ ភាគនៃវិភាគទាន

### ១. និយមន័យ និងគោលគំនិត

ភាគនៃវិភាគទាន គឺសំដៅទៅលើសកម្មភាពដែលសន្តតិជនបានប្រើប្រាស់ជាពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជនដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត។

ជាទូទៅ កាលណាទ្រព្យរបស់មតកជនមិនបាត់បង់ ប្រយោជន៍របស់សន្តតិជនទទួលបានក៏ច្រើនទៅតាមនោះដែរ។ ដូច្នេះ ប្រសិនបើមានសន្តតិជន បានចំណាយនូវធនធានផ្ទាល់ខ្លួន ដើម្បីថែរក្សាទ្រព្យសម្បត្តិរបស់មតកជន នោះផលដែលកើតចេញពីសកម្មភាពនោះ នឹងត្រូវបានទទួលដោយសន្តតិជនផ្សេងទៀតជាក់ជាមិនខាន។ ដូច្នេះ វានឹងមិនមានគុណភាពទេ រវាងសន្តតិជនដែលបានធ្វើភាគនៃវិភាគទាន និងសន្តតិជនដែលមិនបានធ្វើភាគនៃវិភាគទាន ហើយបែរជាទទួលបានចំណែកមត៌កស្មើគ្នានៃពេលចាប់ផ្តើមសន្តតិកម្មនោះ។

*__ឧទាហរណ៍៖__ មតកជន A បានបន្សល់ទឹកប្រាក់ចំនួន ៩០០ ដុល្លារ ជាសន្តតិកម្ម ហើយមានសន្តតិជន X Y និង Z ។ ក្នុងចំណោមសន្តតិជនទាំងបី X បានចំណាយប្រាក់ផ្ទាល់ខ្លួនចំនួន ២០០ ដុល្លារ ដើម្បីជួសជុលផ្ទះរបស់មតកជន នៅពេលដែលមតកជន A ឈឺ។*

*នៅក្នុងឧទាហរណ៍ខាងលើ ប្រសិនគ្មានការសម្រួលចំណែកមត៌កទេ នោះនៅពេលចាប់ផ្តើមសន្តតិកម្ម X Y និង Z នឹងធ្វើសន្តតិកម្មដូចខាងក្រោម៖*

*X ទទួលបានមត៌ក ៩០០/៣ = ៣០០ ដុល្លារ*

*Y ទទួលបានមត៌ក ៩០០/៣ = ៣០០ ដុល្លារ*

*Z ទទួលបានមត៌ក ៩០០/៣ = ៣០០ ដុល្លារ*

*នៅក្នុងការបែងចែកខាងលើនេះ ហាក់បីដូចជាមានភាពស្មើគ្នារវាងសន្តិជន ប៉ុន្តែ សូមកុំភ្លេចថា នៅមុនពេលសន្តតិកម្មបានចាប់ផ្តើម សន្តតិជន X បានចំណាយនូវប្រាក់ផ្ទាល់ខ្លួនចំនួន ២០០ ដុល្លារ ដើម្បីប្រយោជន៍រួម។ ដូចនេះ ប្រសិនបើពិចារណាឲ្យស៊ីជម្រៅ សន្តតិជនទទួលបានផលប្រយោជន៍ពីសន្តតិកម្មតែទឹកប្រាក់ចំនួន ១០០ ដុល្លារ តែប៉ុណ្ណោះ។ ត្រង់ចំនុចនេះហើយ ដែលវាបានកើតឡើងនូវភាពមិនស្មើគ្នារវាងសន្តតិជន។*

*ជាដំណោះស្រាយ ត្រូវមានការសម្រួលចំណែកមត៌ក ក្នុងករណីដែលសន្តតិជនបានធ្វើភាគនៃវិភាគទាន។*

បើយោងទៅតាមអត្ថន័យខាងលើ សន្តតិជនអាចធ្វើភាគនៃវិភាគទានចំពោះមតកជន តាមប្រភេទផ្សេងៗគ្នា ដូច្នេះចំនុច (២) ខាងក្រោមនេះនឹងធ្វើការបកស្រាយពីប្រភេទនៃវិភាគទាន។

### ២. ប្រភេទនៃវិភាគទាន

ការធ្វើវិភាគទាន មិនមែនសំដៅតែការផ្តល់ប្រាក់ចំពោះមតកជនតែមួយមុខនោះទេ។ ភាគនៃវិភាគទានអាចជា ការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន (២.១) ការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ (២.២) ការថែទាំព្យាបាលមតកជន (២.៣) វិធីផ្សេងៗទៀត (២.៤)។

#### ២.១ ការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន

សន្តតិជនអាចធ្វើការជួយគ្រប់គ្រង និងការពារទ្រព្យសម្បត្តិរបស់មតកជន មិនឲ្យបាត់បង់ ឬវិនាសនៅពេលដែលមតកជនមានភារកិច្ចមិនអាចបំពេញការងារ ឬនៅពេលដែលមតកជនមាន ជំងឺ។

***ឧទាហរណ៍៖*** *លោក **ក** មានជំងឺលើសឈាមធ្វើឲ្យស្លាប់មួយចំហៀងខ្លួនមិនអាចទៅបំពេញការងារបាន។ លោក **ក** មានកូន២នាក់គឺ **ខ** និង **គ** ។ ដោយឪពុកមិនអាចបំពេញការងារកើត លោក **គ** ក៏បានទៅបំពេញការងារជំនួសដើម្បីកុំឲ្យក្រុមហ៊ុនខាត់បង់ ឬក្ស័យធន។ ទង្វើរបស់លោក **គ** គេអាចចាត់ទុកជាភាគនៃវិភាគទាន ព្រោះទង្វើនេះជួយដល់ជីវភាពទាំងមូលរបស់គ្រួសារ។*

#### ២.២ ការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ

ភាគនៃវិភាគទាន ដោយការជួយរកស៊ីមតកជនគឺ សន្តតិជនជួយរកស៊ី ដោយលះបង់ពេលវេលាផ្ទាល់ខ្លួន ដែលធ្វើឲ្យទ្រព្យសម្បត្តិរបស់មតកជនកើនឡើង នឹងមិនធ្វើឲ្យមានការខាត់បង់នូវទ្រព្យសម្បត្តិរបស់មតកជនឡើយ។

***ឧទាហរណ៍៖*** *គ្រួសារមួយមានសមាជិក៥នាក់ឪពុកម្តាយនិងកូន៣នាក់គឺ **ក ខ** និង **គ** ។ ជាអកុសលឪពុកម្តាយរបស់ពួកគេបានជួបគ្រោះថ្នាក់ចរាចរណ៍បណ្តាលឲ្យឪពុកស្លាប់។ គ្រួសារបាត់បង់ជំហរម្តាយរបស់ពួកគេជាអ្នករកស៊ីចិញ្ចឹមគ្រួសារតែម្នាក់ឯង ដោយសារតែជីវភាពក្រលំបាកពេក លោក **ក** ដែលជាកូនច្បងក៏បានបោះបង់ចោលការសិក្សាជួយរកស៊ីម្តាយ ដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ និងដើម្បីផងឲ្យប្អូនៗបានបន្តការសិក្សា។ ទង្វើរបស់លោក **ក** អាចចាត់ទុកជាភាគនៃវិភាគទានពិសេស ព្រោះការលះបង់ របស់គាត់អាចជួយជីវភាពគ្រួសាររបស់ទាំងមូល។*

**២.៣ ការថែទាំព្យាបាលមតកជន**

ការផ្តល់ដើមទុនរកស៊ីរបស់សន្តតិជន ទៅឲ្យមតកជនក៏ជាផ្នែកមួយនៃភាគនៃវិភាគទានផងដែរ។ ក្នុងករណីដែលសន្តតិជនជូនប្រាក់ដល់មតកជនក្នុងឱកាសបុណ្យទានតើវាជាការផ្តល់ដើមទុនរកស៊ីដែរ រឺទេ? ការជូនប្រាក់ទៅមតកជនក្នុងឱកាសបុណ្យទានវាមិនអាចចាត់ទុកថាជាការផ្តល់ដើមទុននោះទេ។ ព្រោះវាជាទង្វើធម្មតាដែលកូនជូនប្រាក់ឪពុកម្តាយក្នុងឱកាសណាមួយ។ ប៉ុន្តែនៅក្នុងករណីមួយដែលសន្តតិជនបានផ្តល់ ប្រាក់ដើម្បីឲ្យមតកជនបង្កើតនូវមុខជំនួញណាមួយនោះទើបអាចចាត់ទុកថាជាភាគនៃវិភាគទានដោយការផ្តល់ដើមទុនរកស៊ី។ ព្រោះប្រសិនបើពុំមានការផ្តល់ដើមទុនពីសន្តតិជនទេនោះ មតកជនក៏មិនអាចធ្វើការបង្កើតនូវមុខជំនួញឲ្យកាន់តែធំ ឬធ្វើការពង្រឹងមុខជំនួញឲ្យកាន់រឹងមាំបន្ថែមទៀតនោះទេ។ មិនតែប៉ុណ្ណោះធ្វើឲ្យប្រាក់ចំណូលរបស់មតកជនមានការកើនឡើង។

**២.៤ វិធីផ្សេងៗទៀត**

ភាគនៃវិភាគទានជាការថែទាំ គឺសន្តតិជនណាម្នាក់បានលះបង់នូវពេលវេលាដើម្បីមើលថែរក្សាមតកជន និងធ្វើការចំណាយថវិកាផ្ទាល់ខ្លួនដើម្បីព្យាបាលជំងឺរបស់មតកជន។ ការធ្វើបែបនេះធ្វើឲ្យទ្រព្យសម្បត្តិរបស់មតកជនមិនបាត់បង់ ចំពោះការចំណាយទៅលើការមើលថែរក្សា នឹងថ្លៃនៃការព្យាបាលជំងឺ។ ម្យ៉ាងវិញទៀត ទោះជាបានផ្តល់សេវាកម្មលើកិច្ចការរបស់មតកជនក៏ដោយ តែប្រសិនបើបានទទួលនូវតម្លៃថ្នូរវិញចំពោះសេវាកម្ម នោះមិនអាចចាត់ទុកជាភាគនៃវិភាគទានពិសេសបានទេ។

| |
|---|
| ***<u>ឧទាហរណ៍៖</u>*** *ដោយសារតែការថែរក្សាព្យាបាលនោះ មតកជនអាចបន្ថយការចំណាយក្នុងការជួលអ្នកមើលថែរក្សា ហើយនេះជាកត្តាមួយដែលអាចរក្សាទ្រព្យសម្បត្តិរបស់មតកជនបាន។* |

**៣. វិធីនៃការសម្រួលចំណែកមត៌ក**

វិធីនៃការសម្រួលចំណែកមត៌ក ក្នុងករណីភាគនៃវិភាគទានដើម្បីធ្វើឲ្យមានភាពស្មើគ្នារវាងសហសន្តតិជនទាំងអស់។ វិធីនៃការសម្រួលចំណែកមត៌កធ្វើទៅតាមដំណាក់ការ ដូចខាងក្រោម៖ ការគណនាតម្លៃនៃមត៌កក្នុងករណីមានភាគនៃវិភាគទាន (៣.១) និងការបូកបន្ថែមតម្លៃភាគនៃវិភាគទានលើចំណែកមត៌ករបស់សន្តតិជនដែលបានធ្វើភាគនៃវិភាគទាន (៣.២)។

### ៣.១ ការគណនាតម្លៃនៃមត៌កក្នុងករណីមានភាគនៃវិភាគទាន

វិធីសាស្ត្រនៃការគណនាចំណែកមត៌ក ក្នុងករណីដែលមានភាគនៃវិភាគទានមានដូចខាងក្រោម៖

ដំបូង ត្រូវដកចំនួនទឹកប្រាក់នៃភាគនៃវិភាគទាន ពីមត៌ករបស់មតកជន ទ្រព្យដែលនៅសល់ពីការដកតម្លៃនៃភាគនៃវិភាកទានចេញ ជាមត៌កសរុប។ បន្ទាប់មកយើងត្រូវធ្វើការគណនា ចំណែកមត៌ករបស់សន្តតិជននីមួយៗ ស្របទៅតាមច្បាប់កំណត់។

*__ឧទាហរណ៍៖__ លោក A មានកូនពីរនាក់ គឺ X និងY ។ លោក X បានធ្វើភាគនៃវិភាគទានទៅឲ្យលោក A ចំនួន ១០០០ ដុល្លារ។ មុនពេលដែលលោក A ទទួលមរណភាពគាត់បានបន្សល់ទុក ប្រាក់ចំនួន ២០០០ ដុល្លារ។*

*នាំឲ្យមត៌កសរុប = ២០០០-១០០០= ១០០០ដុល្លារ*

*សន្តតិជនទទួលបាន១/២ ម្នាក់ យើងអាចទាញបានថា៖*

*លោក Y ទទួលបាន ១០០០/២ = ៥០០ដុល្លារ*

*លោក X ទទួលបាន ១០០០/២ = ៥០០ ដុល្លារ ប៉ុន្តែ លោក X បានធ្វើភាគនៃវិភាគទានចំនួន១០០០ ដុល្លារ ដូច្នេះ មត៌កសរុបរបស់លោក X = ១៥០០ ដុល្លារ។*

### ៣.២ ចំណែកមត៌ករបស់សន្តតិជនដែលបានធ្វើភាគនៃវិភាគទាន

វិធីគណនាចំណែកមត៌ក របស់សន្តតិជនដែលបានធ្វើភាគនៃវិភាគទានគឺ យកតម្លៃមត៌ករបស់សន្តតិជនបូក និងភាគនៃវិភាគទានដែលសន្តតិជនបានធ្វើ។

*__ឧទាហរណ៍៖__ លោក ក មានកូនបីនាក់គឺ A B និង C។ លោក A បានជួយធ្វើជំនួញរបស់លោក ក ឲ្យមានការកើនឡើង ២០០០០ ដុល្លារ។ នៅពេលលោក ក ទទួលមរណភាពគាត់បានបន្សល់ទុក ប្រាក់ ៥០០០០ ដុល្លារ នៅធនាគារ។*




បានធ្វើភាគនៃវិភាគទាន

២០០០០ដុល្លារទៅមតកជន

*សន្តតិជនម្នាក់ទទួលបាន១/៣ ម្នាក់*

*⇨ដូច្នេះដោយមតិកសរុប = ៥០០០០ - ២០០០០ = ៣០០០០ ដុល្លារ*

*→លោក B ទទួលបានមតិក = ៣០០០០/៣=១០០០០ ដុល្លារ*

*→លោក C ទទួលបានមតិក = ៣០០០០/៣ = ១០០០០ដុល្លារ*

*→លោក A ទទួលបានមតិក = ៣០០០០/៣ = ១០០០០ ដុល្លារ ប៉ុន្តែដោយលោក A បានធ្វើភាគនៃវិភាគទាន ចំពោះមតកជនចំនួន២០០០០ ដុល្លារ ។*

*⇨ដូច្នេះ មតិកសរុបរបស់លោក A គឺ ២០០០០ + ១០០០០ = ៣០០០០ ដុល្លារ*

### ៤. តម្លៃនៃវិភាគទាន

យើងបានដឹងរួចហើយថា ក្នុងករណីសន្តតិជនម្នាក់បានធ្វើភាគនៃវិភាគទានចំពោះមតកជន ការសម្រួលចំណែកមតិកត្រូវបានចាប់ផ្តើមដោយយកទ្រព្យសម្បត្តិរបស់មតកជនមាននាពេល ចាប់ផ្តើមសន្តតិកម្ម ដកនឹងតម្លៃភាគនៃភាគនៃវិភាគទាន។ ហើយចំណែកមតិករបស់សន្តតិជនដែលបានធ្វើភាគនៃវិភាគទាន ត្រូវបូកបន្ថែមនូវតម្លៃភាគនៃវិភាគទាននោះ លើចំណែកមតិកនាពេលចាប់ផ្តើមសន្តតិកម្ម។

នៅក្នុងចំណុចនេះ បញ្ហានៅត្រង់ថា "តម្លៃភាគនៃវិភាគទាន"។ តើមានមូលដ្ឋានអ្វីខ្លះដើម្បីកំណត់តម្លៃភាគនៃវិភាគទាន?

មូលដ្ឋានដែលអាចកំណត់តម្លៃភាគនៃវិភាគទាន ដែលអាចប្រព្រឹត្តទៅបានមានដូចជា ការពិភាក្សារបស់សហសន្តតិជន (៤.១) ការកំណត់ភាគនៃវិភាគទានដោយតុលាការ (៤.២)។

#### ៤.១ ការពិភាក្សារបស់សហសន្តតិជន

ក្នុងករណីនេះ សហសន្តតិជនត្រូវធ្វើការកំណត់តម្លៃនៃភាគនៃវិភាគទានដែលមានសន្តតិជនណាម្នាក់ បានធ្វើភាគនៃវិភាគទានពិសេសចំពោះមតកជន ក្នុងអំឡុងពេលមតកជននៅមានជីវិតដោយផ្តល់ថវិកា ឬក៏ដោយសារការថែរក្សាព្យាបាលនោះ មតកជនអាចកាត់បន្ថយការចំណាយក្នុងការជួយមើលថែរក្សា ហើយនេះជាកត្តាមួយដែលអាចបន្ថយការចំណាយ និងជួយថែរក្សាទ្រព្យសម្បត្តិរបស់មតកជនបាន។ ដើម្បីឲ្យមានភាពស្មើគ្នា រវាងសហសន្តតិជន មុននឹងធ្វើការបែងចែក យើងត្រូវរកនូវមតិកសរុបជាមុនសិន ដោយធ្វើការដកភាគនៃវិភាគទានចេញ ប្រគល់ទៅឲ្យសន្តតិជនដែលបានធ្វើភាគនៃវិភាគទាននោះវិញ។

ដូចនេះតម្លៃនៃមតិកសរុប=តម្លៃនៅពេលចាប់ផ្តើមសន្តតិកម្ម-តម្លៃនៃវិភាគទាន។

***ឧទាហរណ៍៖*** *មតកជនមុនពេលស្លាប់បានបន្សល់ទុកនូវទ្រព្យចំនួន ១០០០០ដុល្លារ គាត់មានកូន បួននាក់ គឺ A, B,C និង D ។ អំឡុងពេលដែលមតកជននៅរស់ A បានធ្វើវិភាគទានសម្រាប់ការថែទាំមតកជនចំនួន ២០០០ ដុល្លារ។*

*ដូច្នេះតម្លៃនៃមតិកសរុប=១០០០០-២០០០= ៨០០០ដុល្លារ។*

*ដោយសន្តតិជនមានកូន៤នាក់ហើយមតិកសរុបរបស់មតកជនមាន ៨០០០ ដុល្លារ នាំឲ្យសន្តតិជនម្នាក់ៗទទួលបានមតិក ២០០០ ដុល្លារម្នាក់។ ប៉ុន្តែក្នុងករណីខាងលើ A បានធ្វើវិភាគទានចំពោះមតកជនចំនួន ២០០០ ដុល្លារ ដូច្នេះមតិកដែលA ត្រូវទទួលបានគឺ*

*២០០០+២០០០=៤០០០ដុល្លារ*

### ៤.២ ការកំណត់ភាគនៃវិភាគទានដោយតុលាការ

ក្នុងករណីសហសន្តតិជនធ្វើការពិភាក្សា ចំពោះការបែងចែកមតិកពុំបានសម្រេច ឬ ក្នុងករណីសហសន្តតិជនមិនអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ឲ្យធ្វើការបែងចែកមតិកនោះបាន។ តុលាការមិនអាចធ្វើការបែងចែកមតិកដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ ពោលគឺអាចធ្វើបានតែពេលដែលមានពាក្យសុំពីសហសន្តតិជនប៉ុណ្ណោះ។ សហសន្តតិជនម្នាក់ ឬ ច្រើនអ្នក អាចធ្វើពាក្យសុំឲ្យតុលាការធ្វើការបែងចែកមតិក ចំពោះសហសន្តតិជនទាំងអស់ផ្សេងទៀតដែលជាភាគីម្ខាងទៀតបាន។[43]

ជាគោលការណ៍ នៃការបែងបែកមតិករវាងសហសន្តតិជន ព្រមជាមួយគ្នានេះ ក៏ជាគោលការណ៍នៃការបែងចែកមតិកដោយតុលាការដែរ។ លើសពីនេះតុលាការត្រូវពិចារណាដល់ ទំនៀមទម្លាប់នៅក្នុងតំបន់ និងមតិភាគច្រើនលើសពីពាក់កណ្តាលរបស់សហសន្តតិជន ផងដែរ។ ចំពោះមតិភាគច្រើនលើសពីពាក់កណ្តាលរបស់សហសន្តតិជន ករណីភាគច្រើនដែលបានចាប់ផ្តើមធ្វើការពិភាក្សាដើម្បីបែងចែកមតិក តែមិនអាចធ្វើទៅបានទេនោះ គឺដោយសារតែក្នុងចំណោមសហសន្តតិជនមានសហសន្តតិជនណាម្នាក់ ឬ ភាគតិចនោះមិនសុខចិត្តសម្រុះមតិពិសេសរបស់ខ្លួនទៅនឹងមតិភាគច្រើន។ ប៉ុន្តែទោះបីជាមានមតិភាគច្រើនរបស់សហសន្តតិជនក៏ដោយ ប្រសិនបើមតិនោះមិនសមរម្យទេ ក៏តុលាការមិនត្រូវយកតាមមតិនោះដែរ ហើយទោះបីជាមតិភាគតិចក៏ដោយ ប្រសិនបើសមរម្យ តុលាការគួរស្តាប់តាមមតិភាគតិចនោះដែរ។

[43] មាត្រា១២៧០ សេចក្តីកំណត់ក្រមមាត្រានីមួយក្រមរដ្ឋប្បវេណី ភាគ ៦ (គន្លឹះទី៨&៩)

# សេចក្តីសន្និដ្ឋាន

នៅក្នុងប្រទេសកម្ពុជា របបសន្តតិកម្ម គឺជារបបមួយដែលមានការបែងចែកមតិករបស់អ្នកដែលទទួលមរណភាព ទៅឲ្យអ្នកដែលមានទំនាក់ទំនងខ្សែញាតិផ្ទាល់ ដែលអាចហៅបានថាជាសន្តតិជន។ ប៉ុន្តែ មុននឹងឈានដល់ការក្លាយជាសន្តតិជនបានលុះត្រាតែបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា មានជីវិតរស់នៅ ឬ មិនមែនជាអភ័ព្វបុគ្គល ឬ មិនមែនជាជនដែលត្រូវបានផ្តាច់ចេញពីមតិក។

សន្តតិជនជាបុគ្គលដែលស្ថិតនៅក្នុងទំនាក់ទំនងញាតិក្នុងបីថ្នាក់គឺ បុព្វញាតិផ្ទាល់ បច្ឆាញាតិផ្ទាល់ និងបងប្អូនបង្កើត។ ក្នុងចំណោមញាតិទាំងបីថ្នាក់នេះញាតិដែលមានលំដាប់សន្តតិជនមុនដំបូងគេគឺ បច្ឆាញាតិផ្ទាល់ ដែលជាកូនរបស់មតកជន (សន្តតិជនលំដាប់ទី១) បន្ទាប់មកគឺបុព្វញាតិផ្ទាល់ ដែលជាឪពុកម្តាយបង្កើត ឬ ជីដូនជីតារបស់មតកជន (សន្តតិជនលំដាប់ទី២) និងសន្តតិជនដែលមានលំដាប់ក្រោយគេ គឺបងប្អូនបង្កើត (សន្តតិជនលំដាប់ទី៣)។

ម៉្យាងវិញទៀត ទោះបីមានសន្តតិជនរួចទៅហើយក៏ដោយ ក៏ការបែងចែកមតិកនៅប្រទេសកម្ពុជា ត្រូវបានគេកំណត់យកនូវវិធីបែងចែកមតិកជាពីរគឺ ការបែងចែកចំណែកមតិកតាមច្បាប់ (ឬអាចហៅម្យ៉ាងទៀតថា សន្តតិកម្មតាមច្បាប់ ឬ សន្តតិកម្មឥតបណ្តាំ) និងការបែងចែកចំណែកមតិកតាមឆន្ទៈរបស់មតកជន (ហៅថាសន្តតិកម្មមានបណ្តាំ)។ ចំពោះការបែងចែកមតិកតាមច្បាប់កំណត់គឺជាការបែងចែកមតិករបស់មតកជនទៅតាមកម្រិតមួយដែលច្បាប់បានកំណត់ទៅតាមលំដាប់នៃសន្តតិជន ឬ ចំនួននៃសន្តតិជន ដូចទៅនឹងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ ទន្ទឹមនឹងនោះមតកជនផ្ទាល់ក៏អាចធ្វើការបែងចែកមតិកទៅតាមមតកសាសន៍បានផងដែរ ដោយអាចធ្វើតាមការកំណត់វិធីបែងចែក និងការកំណត់ចំណែកតែម្តង។ ការបែកចែកមតិកករណីមានបណ្តាំ វាមានភាពងាយស្រួលចំពោះសន្តតិជន ព្រោះមតកជនបានធ្វើការបែងចែក ចំណែកឲ្យសន្តតិជនម្នាក់ៗរួចទៅហើយនៅក្នុងបណ្តាំមតកសាសន៍។ សន្តតិជនគ្រាន់តែអនុវត្តទៅតាមមតកសាសន៍ដែលមតកជនទុកឲ្យជាការស្រេច។

ទោះបីមានរបៀបនៃការបែងចែកចំណែកមតិកមានច្រើនរបៀប ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការបែងចែក មិនថាមានបណ្តាំ ឬ ឥតបណ្តាំក្តី ក៏នៅតែមានភាពមិនតុល្យភាពកើតឡើងដែរ ដូចជាការដែលសន្តតិជនបានទទួលផលប្រយោជន៍ពិសេសមុនការចាប់ផ្តើមសន្តតិកម្ម។ ដូចនេះទើបមានការសម្រួលចំណែកមតិក ចូលមកធ្វើការគ្រប់គ្រងការបែកចែកជំនួស។

ការសម្រួលចំណែកមតិក គឺជាវិធីមួយដែលជួយសម្រួលដល់សន្តតិជនដើម្បីឲ្យ សន្តតិជននីមួយៗទទួលបាននូវចំណែកមតិកស្មើៗគ្នា ព្រោះមានករណីខ្លះសន្តតិជនខ្លះបានទទួលនូវផល

ប្រយោជន៍ពិសេស ដែលជាប្រទានកម្មក្នុងឱកាសពិសេសណាមួយ ដូចជាអាពាហ៍ពិពាហ៍ មូលធននៃជីវិត ឬ ហេតុការណ៍ផ្សេងៗដូចជា ការផ្តល់អាហារកិច្ចដល់កូនណាម្នាក់លើសពីកូនផ្សេងទៀតជាដើម។ មានន័យថាសន្តតិជននោះបានទទួលនូវចំណែកមត៌កដែលជាប្រទានកម្មនៅពេលដែលមតកជននៅរស់មួយចំនួនរួចទៅហើយ។ ផ្ទុយទៅវិញប្រសិនបើនៅក្នុងឱកាសផ្សេងទៀតដូចជាឱកាសខួបកំណើត បង្កក់កូន ឡើងផ្ទះ អំណោយដែលទទួលបាននៅពេលនោះមានលក្ខណៈតិចតួច ដូច្នេះគេមិនចាត់ទុកវាជាផលប្រយោជន៍ពិសេសនោះទេ។ ប៉ុន្តែសម្រាប់ការលើកជំនូនដែលជាប្រពៃណីជាតិមួយដែលតម្រូវឲ្យបុរសទៅដណ្តឹងនារី យើងអាចពិចារណាលើស្ថានភាពនេះ ថាជាផលប្រយោជន៍ពិសេស។

មួយវិញទៀតក្នុងករណីភាគនៃវិភាគទាន ក៏ជាផ្នែកមួយនៃការសម្រួលចំណែកមត៌កដែរ ព្រោះសន្តតិជនខ្លះបានចំណាយនូវទ្រព្យផ្ទាល់ខ្លួន ដើម្បីមើលថែរក្សាមតកជន នៅពេលមតកជនមានជំងឺ ធ្វើឲ្យមត៌ករបស់មតកជនមិនមានការបាត់បង់ ឬ ជួយផ្តល់ជាដើមទុនដល់មតកជន ធ្វើមត៌ករបស់មតកជនមានការកើនឡើង។ ភាគនៃវិភាគទានមានច្រើនប្រភេទដូចជា ការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ការផ្តល់តារកាលិកលើទ្រព្យសម្បត្តិ ការថែទាំព្យាបាលមតកជន និងវិធីផ្សេងៗទៀត។ ដូចនេះរាល់ការចំណាយបែបនេះ ប្រសិនបើចំណែកមត៌ករបស់សន្តតិជនម្នាក់ៗនៅតែទទួលបានចំណែកស្មើៗគ្នានោះ នោះហាក់បីដូចជាធ្វើឲ្យសន្តតិជនដែលបានធ្វើភាគនៃវិភាគទានមានការខាតបង់។ ដូចនេះ នឹងតម្រូវឲ្យមានការបង្វិលនូវភាគនៃវិភាគទានឡើងមកវិញសម្រាប់សន្តតិជន។

ដោយមូលហេតុខាងលើនេះហើយ ទើបក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចែងពីការសម្រួលចំណែកមត៌កនេះឡើង ព្រមទាំងធ្វើការសម្រួលនូវវិវាទមួយចំនួនដែលទាក់ទងនឹងសន្តតិកម្ម ឲ្យមានភាពធូរស្រាលនាពេលអនាគត។ នឹងម៉្យាងវិញទៀត ដើម្បីជួយសម្រួលដល់សហសន្តតិជនទាំងអស់ អាចទទួលបាននូវភាពយុត្តិធម៌ និងមិនលំអៀងទទួលយកដោយការពេញចិត្ត។

# អនុសាសន៍

តាមរយៈការស្វែងយល់ និងបទពិសោធក្នុងការសិក្សាស្រាវជ្រាវខាងលើ អាចទទួលបាន និងផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីដោះស្រាយបញ្ហាមិនច្បាស់លាស់ ព្រមទាំងធ្វើឲ្យការអនុវត្តច្បាប់ខាងលើមានលក្ខណៈងាយស្រួលជាងមុនដូចខាងក្រោមៈ

ដូចដែលបានបកស្រាយខាងលើ ចំណែកមតិក និងការសម្រួលចំណែកមតិក អាចកំណត់បាននូវបញ្ហាអំពីការកំណត់នូវអត្ថន័យ ក៏ដូចជាភាពល្អៀងមួយចំនួន។ ផលប្រយោជន៍ពិសេស ត្រូវបានគេកំណត់ថាជា ប្រទានកម្មក្នុងឱកាសពិសេស ដូចជាអាពាហ៍ពិពាហ៍ មូលធននៃជីវិត ឬ ក្នុងហេតុការណ៍ផ្សេងៗ។ ក្នុងន័យនេះដែរ នៅក្នុងក្រមរដ្ឋប្បវេណី ក៏ដូចជាសទ្ធានុក្រម មិនមានការបកស្រាយឲ្យបានច្បាស់លាស់នោះទេ អំពីខ្លឹមសារនៃផលប្រយោជន៍ពិសេស។ ដោយសារតែច្បាប់មិនបាន ធ្វើការកំណត់ឲ្យបានច្បាស់លាស់ឡើយ ទើបមានតែការបកស្រាយ របស់សាស្ត្រាចារ្យច្បាប់ មេធាវី និងឆន្ទានុសិទ្ធិរបស់តុលាការ ប៉ុណ្ណោះ។ ដោយសារតែមិនមានការកំណត់ច្បាស់លាស់នេះហើយ ទើបធ្វើឲ្យការអនុវត្តមានភាពខ្វែងគំនិតគ្នាមួយចំនួន។ ដូចនេះយើងគួរធ្វើការកំណត់បានច្បាស់លាស់អំពីផលប្រយោជន៍ពិសេស ថាជាប្រទានកម្មណាមួយឲ្យបានជាក់លាក់។ មួយវិញទៀត ត្រូវស្វែងយល់ និងបញ្ជាក់ឲ្យច្បាស់ពី ប្រទានកម្មពិសេសក្នុងហេតុការណ៍ផ្សេង ព្រោះនៅក្នុងហេតុការណ៍ផ្សេងៗ មានច្រើនហេតុការណ៍ ដូចជា ការស្តីដណ្តឹងដែលជាប្រពៃណីទំនៀមទម្លាប់ជាតិជាដើម។

មួយវិញទៀត ត្រូវសិក្សាអំពី ទំហំនៃផលប្រយោជន៍ពិសេស។ ជាក់ស្តែង នៅក្នុងការអនុវត្តន៍សព្វថ្ងៃ ទំហំនៃផលប្រយោជន៍ពិសេស មិនមែនជាបញ្ហាដែលត្រូវចោទនោះទេ ប៉ុន្តែសម្រាប់នាពេលអនាគតនឹងមានការខ្វែងគំនិតគ្នាអំពីទ្រឹស្តី ព្រមការសម្រេចរបស់តុលាការ។ យើងគួរគប្បីបង្ហាញជាលក្ខណបណ្តុះអាសន្នសិនបានថា ប្រទានក្នុងឱកាសពិសេស ដែលមតកបានប្រគល់ទៅឲ្យសន្តតិជន ជាកម្រិតនៃប្រាក់របស់មតកជន ឬ ប៉ុន្មានភាគនៃកម្រិតទ្រព្យសម្បត្តិជាដើម។ មួយវិញទៀត ទំហំនៃផលប្រយោជន៍ពិសេស អាចវិនិច្ឆ័យទៅតាមស្ថានភាពសេដ្ឋកិច្ចរបស់មតកជន ឬ អាចកំណត់ជាការប្រគល់នូវដីធ្លី ការប្រគល់ផ្ទះ ជាដើម។

ម៉្យាងវិញទៀតទាក់ទងទៅនឹងភាគនៃវិភាគទាន នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់ថា ប្រសិនបើសន្តតិជនណាម្នាក់បានធ្វើភាគនៃវិភាគទាន នោះនៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវបង្វិលនៅភាគនៃវិភាគទាននោះទៅឲ្យសន្តតិជនវិញបាន។ តួយ៉ាង ប្រសិនបើការបែងចែកមតិកតាមច្បាប់ភាគនៃវិភាគទានមានទំហំធំជាងមតិកនោះ នោះសន្តតិជនដែលបានធ្វើភាគនៃវិភាគទានត្រូវទទួលចំណែកមតិកទាំងអស់។ ប៉ុន្តែប្រសិនបើមតកជនបានធ្វើមតកសាសន៍ឲ្យចំណែកមតិកមួយភាគធំ

ដែលលើសពីភាគនៃវិភាគទាន នោះអ្នកដែលបានធ្វើភាគនៃវិភាគទានមានសិទ្ធិទទួលបានត្រឹមចំណែកដែលនៅសល់តែប៉ុណ្ណោះ។ ត្រង់ចំនុចនេះគ្មានការបកស្រាយនោះទេ ហាក់ដូចជាមានភាគលំអៀង ប៉ុន្តែយើងអាចយល់បានថា នៅក្នុងក្រមរដ្ឋប្បវេណី មានគោលការណ៍គោរពនៅឆន្ទៈរបស់មតកជនជាធំ នឹងការធ្វើភាគនៃវិភាគទានគឺជាឆន្ទៈរបស់សន្តតិជនផ្ទាល់ដែលបានធ្វើដោយមិនរំពឹងតម្លៃតបស្នងមកវិញ។ ពោលគឺ ភាគនៃវិភាគទានធំជាងចំណែកមតិក តែភាគនៃវិភាគទានតូចជាងឆន្ទៈរបស់មតកជន។ ជាក់ស្តែង ផលប្រយោជន៍ពិសេសក៏ដូចគ្នា ប្រសិនបើប៉ះពាល់ដល់ភាគបម្រុង នោះត្រូវបង្វិលផលប្រយោជន៍ពិសេសមកវិញជាដាច់ខាត ដោយធ្វើការសម្រួល ប៉ុន្តែប្រសិនបើមិនមានការប៉ះពាល់ទេ នោះមិនចាំបាច់បង្វិលមកវិញនោះទេ។

ដូចនេះ ឆ្លងតាមរយៈការស្រាវជ្រាវ ចំណែកមតិក និងការសម្រួលចំណែកមតិកពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់នៅក្នុងរបបសន្តតិកម្ម ក៏ដូចជាចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដើម្បីអនុវត្តនាពេលបច្ចុប្បន្ន និងនាថ្ងៃអនាគត។ ប៉ុន្តែទោះយ៉ាងនេះក៏ដោយក្តី ក៏យើងសង្កេតឃើញថា មានមាត្រាខ្លះមិនទាន់មានខ្លឹមសារគ្រប់គ្រាន់ ក៏ដូចជាគ្មានការពន្យល់បកស្រាយនូវចំនុចមួយចំនួន ព្រមទាំងមានមាត្រាខ្លះចែងមកមានភាពស្រពិចស្រពិល ដូច្នេះ យើងសង្ឃឹមថាចំនុចទាំងនោះនឹងត្រូវបានពិចារណា ព្រមទាំងលើកយកមកកែសម្រួលដើម្បីអនុវត្តនាពេលខាងមុខជាមិនខាន។ យើងខ្ញុំសង្ឃឹមថា ចំណែកមតិក និងការសម្រួលចំណែកមតិកនឹងមានការចាប់អារម្មណ៍ពីសំណាក់មនុស្សជាតិទូទៅ។

# ឯកសារយោង

## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិជាតិ


- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ភូមិបាល ២០០១
- ច្បាប់ស្ដីពីការផ្ដល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស


## សៀវភៅ និង អត្ថបទផ្សេងៗ


- សមាជិកក្រុមការងារគ្រូបណ្ដុះបណ្ដាលនៃសាលាភូមិន្ទចៅក្រម ដោយមានការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការ JICA, *ក្រមរដ្ឋប្បវេណី ភាគ ៦*, (ភ្នំពេញ៖ លើកទី ១, ២០១២)។
- សាស្ត្រាចារ្យ ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ, *សេចក្ដីផ្ដើមរដ្ឋប្បវេណី*, (ភ្នំពេញ៖ លើកទី ៥, ២០១១)។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ : គន្ថីទី ៨-ទី៩*, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១០)។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១ : គន្ថីទី ១-ទី៣*, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១០)។

# ឧបសម្ព័ន្ធ

## ច្បាប់ភូមិបាល ២០០១

**មាត្រា៨**

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់ កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។

អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីកម្ពុជាគឺពលរដ្ឋខ្មែរទាំង អស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជាដែលបានទទួលស្គាល់ដោយ ច្បាប់ថាជានីតិបុគ្គល។

ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឲ្យក្លាយជា កម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥១ នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសទុកជាសម្បត្តិ រដ្ឋ ដោយរដ្ឋមិនចេញសំណងឱ្យឡើយ។

**ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស**

**មាត្រា៦**

ជនបរទេសមានសិទ្ធិកម្មសិទ្ធិ លើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ (មួយ) ឡើងទៅ។ ជាន់ផ្ទាល់ដី និងជាន់ក្រោមដីមិនត្រូវបានអនុញ្ញាតឲ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ។

ចំពោះអគារសហកម្មសិទ្ធិមួយកន្លែង សមាមាត្រ និងរបៀបគិតគូរនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ។

ការផ្តល់កម្មសិទ្ធិនេះ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែមួយប៉ុណ្ណោះ។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៅក្នុងអគារសហកម្មសិទ្ធិប្រើប្រាស់រួម។

ក្នុងករណីណាក៏ដោយ ក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនេះក៏មិនអាចជាកម្មវត្ថុ នៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសបានឡើយ។

ជនបរទេស នឹងត្រូវបានអនុញ្ញាតឲ្យមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតក្នុងចម្ងាយ៣០ (សាបសិប) គីឡូម៉ែត្រពីព្រំដែនគោកឡើយ និងតំបន់មួយចំនួនទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និងតំបន់ផ្សេងទៀតដែលកំណត់ដោយរដ្ឋាភិបាល។

ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី៣ ជនបរទេសអាចមានសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចពលរដ្ឋខ្មែរដែរ។